ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារគោល

# នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំង

# អំពើជួញដូរមនុស្ស

# សម្រាប់អនុវត្តឆ្នាំ២០១៧-២០១៨

**កែសម្រួលសម្រាប់ឆ្នាំ២០១៧-២០១៨**

# ពាក្យសរសេរកាត់

| | |
|---|---|
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់ជាតិ |
| COMMIT | គំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីក្នុងតំបន់ទន្លេមេគង្គដែលមានការសម្របសម្រួលប្រឆាំងនឹងអំពើជួញដូរមនុស្ស |
| CTIP | ការប្រឆាំងនឹងអំពើជួញដូរមនុស្ស |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IOM | អង្គការអន្តរជាតិទេសន្តរប្រវេសន៍ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoFAIC | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MoJ | ក្រសួងយុត្តិធម៌ |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoVSY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoT | ក្រសួងទេសចរណ៍ |
| MoWA | ក្រសួងកិច្ចការនារី |
| NC-STSLS | គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ |
| NCS | លេខាធិការដ្ឋានគណៈកម្មាធិការជាតិ(មុន ខែមិថុនា ឆ្នាំ២០១៤) |
| NPA | ផែនការសកម្មភាពជាតិ |
| P/MC | គណៈកម្មាធិការខេត្ត/រាជធានី |
| P/MCS | លេខាធិការដ្ឋានគណៈកម្មាធិការខេត្ត/រាជធានី |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| STSLS | ការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ |
| UNACT | អង្គការសហប្រជាជាតិដើម្បីសហប្រតិបត្តការប្រឆាំងអំពើជួញដូរមនុស្ស |

| | |
|---|---|
| UN WOMEN | អង្គការសហប្រជាជាតិដើម្បីសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| UNODC | ការិយាល័យប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អង្គការសហប្រជាជាតិ |
| USAID | ទីភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក |

# មាតិកា

ពាក្យសរសេរកាត់ ........ I
សារលិខិត របស់ប្រធានគណៈកម្មាធិការជាតិ ........ IV
**ឯកសារគោល នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តឆ្នាំ២០១៧-២០១៨ ... 1**
**ក.សេចក្តីផ្តើម ........ 1**
ក.១. មូលហេតុនៃការកែសម្រួលផែនការសកម្មភាពជាតិ សម្រាប់ឆ្នាំ២០១៧-២០១៨ ........ 1
ក.២. មូលដ្ឋានបង្អែកនៃការកែលម្អផែនការសកម្មភាពជាតិ២០១៧-២០១៨ ........ 1
ការរៀបចំផែនការសកម្មភាពជាតិសម្រាប់ឆ្នាំ២០១៧-២០១៨ គឺផ្អែកលើ៖ ........ 1
**ខ. ផែនការសកម្មភាពជាតិប្រឆាំងនឹងអំពើជួញដូរមនុស្ស សម្រាប់ អនុវត្ត ក្នុងឆ្នាំ២០១៤ និង២០១៨ ........ 14**
ខ.១. ទស្សនៈវិស័យ ........ 14
ខ.២. ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ផែនការសកម្មភាពជាតិប្រឆាំងនឹងការជួញដូរមនុស្ស (ឆ្នាំ២០១៤-២០១៨) ........ 14
ខ.៣. គុណតម្លៃស្នូលនៃផែនការសកម្មភាពជាតិ ........ 15
ខ.៤. គោលដៅរួម ........ 17
ខ.៥. យុទ្ធសាស្ត្រនៃផែនការសកម្មភាពជាតិ ........ 17
ខ.៥.១. យុទ្ធសាស្ត្រទី១ ៖ លើកកម្ពស់ការអនុវត្ត ច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ ........ 18
ខ.៥.២. យុទ្ធសាស្ត្រទី២ ៖ លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់ នៃអំពើជួញដូរមនុស្ស ........ 18
ខ.៥.៣. យុទ្ធសាស្ត្រទី៣ ៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹង អំពើជួញដូរមនុស្ស ........ 19
ខ.៥.៤. យុទ្ធសាស្ត្រទី៤ ៖ បង្កើនកិច្ចការពារជនរងគ្រោះ ជាពិសេស ស្ត្រី និងកុមារ ........ 19
យុទ្ធសាស្ត្រទី១ ៖ លើកកម្ពស់ការអនុវត្តច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ ........ 21
យុទ្ធសាស្ត្រទី២ ៖ លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ........ 25
យុទ្ធសាស្ត្រទី៣ ៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបអំពើជួញដូរមនុស្ស ........ 32
យុទ្ធសាស្ត្រទី៤ ៖ លើកកម្ពស់កិច្ចការពារជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ........ 34

# សារលិខិត របស់ប្រធានគណៈកម្មាធិការជាតិ

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៧

ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានស្ថាប័ន អង្គភាព ក្នុងរាជរដ្ឋាភិបាល និង អង្គការដៃគូ ជាតិ និងអន្តរជាតិពាក់ព័ន្ធទាំងអស់ជាទីរាប់អាន

ឯកសារគោលនៃផែនការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តក្នុងឆ្នាំ ២០១៧ និង២០១៨នេះ មានវិសាលភាពគ្របដណ្តប់ទៅគ្រប់សកម្មភាពដែលរួមចំណែកក្នុងការ បង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដើម្បីលើកកម្ពស់សន្តិសុខសុវត្ថិភាព របស់មនុស្សក្នុងសង្គមគ្រប់វ័យ គ្រប់ភេទ ឲ្យជៀសផុតពីអំពើជួញដូរ កេងប្រវ័ញ្ច និងការរំលោភ បំពានទាំងឡាយ ដែលធ្វើឲ្យជនរងគ្រោះធ្លាក់ចូលក្នុងទាសភាពសម័យទំនើប ។

ឯកសារគោលនេះ គឺជាផែនទីបង្ហាញផ្លូវ និងជាមូលដ្ឋានក្នុងការរៀបចំសកម្មភាពនៅតាម ក្រសួង ស្ថាប័ន អង្គភាពនីមួយៗសម្រាប់ឆ្នាំ ២០១៧-២០១៨ ដែលឆ្លើយតបទៅនឹងទស្សនៈវិស័យ និងគោលដៅរួមរបស់ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** (គ.ជ.ប.ជ)។ សកម្មភាពដែល គ្រោងឡើងដោយក្រុមការងារ ក្រសួង ស្ថាប័ន អង្គភាពនីមួយៗ គឺជាការបញ្ជាក់បន្ថែមនូវការប្តេជ្ញា ចិត្តក្នុងការរួមចំណែកដល់ការបង្ការទប់ស្កាត់ដើមហេតុនាំឲ្យមានបទល្មើសជួញដូរមនុស្ស ដែល ចាំបាច់ត្រូវរួមគ្នាលុបបំបាត់ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ សកម្មភាពទាំងនោះ គប្បីចាប់ផ្តើមពី ការកែលម្អ និងពង្រឹងតួនាទីស្ថាប័នក្នុងការគ្រប់គ្រង និងអនុវត្តភារកិច្ច ឲ្យបានល្អប្រសើរ ដើម្បី បង្កើនភាពជឿជាក់ កក់ក្តៅរបស់ប្រជាពលរដ្ឋក្នុងការទទួលសេវា និងមិនបង្កឲ្យមានភាពថ្នាំងថ្នាក់ និងទ័លច្រករហូតធ្វើការសម្រេចចិត្តដោយប្រថុយប្រថាន ដែលរឹតតែរងគ្រោះថែមទៀត ។

ទទួលបានឯកសារនេះ ខ្ញុំជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងជំរុញ ការរៀបចំផែនការសកម្មភាពលម្អិតតាមស្ថាប័ន និងជំរុញអនុវត្តឲ្យខាងតែបាន ។

ក្នុងនាម**គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះគ្រប់កិច្ច ខិតខំប្រឹងប្រែង យកចិត្តទុកដាក់ធ្វើសកម្មភាពមិនខ្លាចនឿយហត់ដើម្បីប្រឆាំងការជួញដូរមនុស្ស និងសូមលើកទឹកចិត្ត សម្របសម្រួល និងគាំទ្ររាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់របស់គ្រប់អង្គ ភាព ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសូមជូនពរជោគជ័យ និងបវរសួស្តី គ្រប់ៗគ្នា កុំបីខាន ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

**ប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

# ឯកសារគោល
# នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# សម្រាប់អនុវត្តឆ្នាំ២០១៧-២០១៨

## ក.សេចក្តីផ្តើម

### ក.១. មូលហេតុនៃការកែសម្រួលផែនការសកម្មភាពជាតិ សម្រាប់ឆ្នាំ២០១៧-២០១៨

ផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៤-២០១៨ ត្រូវបានរៀបចំ និងអនុវត្តយ៉ាងសកម្មដោយគណៈកម្មាធិការជាតិ(គ.ជ.ប.ជ)គ្រប់លំដាប់ថ្នាក់ រួមមានក្រសួង ស្ថាប័ន អង្គភាព មន្ទីរ ស្ថាប័ន ក្នុងរាជរដ្ឋាភិបាល តាំងពីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិរហូតដល់ឃុំសង្កាត់ និងមានអង្គការដៃគូជាតិ អន្តរជាតិជាច្រើនទៀតចូលរួមផង ។ តួនាទីភារកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចែងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសម្រេចនានា ដែលស្តីពីការបង្កើតយន្តការជាតិ ថ្នាក់ក្រោមជាតិ និងរចនាសម្ព័ន្ធយ៉ាងច្បាស់លាស់ ។

នៅពាក់កណ្តាលឆ្នាំ២០១៦ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយអង្គការវិនរ៉ក់អន្តរជាតិ ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក ដើម្បីឲ្យអ្នកជំនាញវាយតម្លៃឯករាជ្យ ធ្វើការសិក្សាវាយតម្លៃអំពីប្រសិទ្ធភាព និងផលប៉ះពាល់ ឬចំណុចខ្វះខាតផ្សេងៗ ដែលអាចឈានទៅតម្រង់ទិសកែលម្អការអនុវត្តនៅពាក់កណ្តាលអាណត្តិ នៃផែនការបន្តទៅទៀតសម្រាប់ឆ្នាំ២០១៧ និង ២០១៨ ។

លើសពីនេះ អំពើជួញដូរមនុស្សបាន និងកំពុងតែលេចចេញនូវរូបភាពថ្មីៗ ដែលចាំបាច់ត្រូវរិះរកសកម្មភាពថ្មីដែលឆ្លើយតបទៅនឹងបញ្ហាបានល្អប្រសើរ ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានចុះហត្ថលេខាទទួលអនុវត្តនូវអនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន និងប្រទេសពាក់ព័ន្ធដទៃទៀត ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលចាំបាច់ត្រូវអនុវត្តឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ។

### ក.២. មូលដ្ឋានបង្អែកនៃការកែលម្អផែនការសកម្មភាពជាតិ២០១៧-២០១៨

**ការរៀបចំផែនការសកម្មភាពជាតិសម្រាប់ឆ្នាំ២០១៧-២០១៨ គឺផ្អែកលើៈ**

- លទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការ ដែលបានធ្វើឡើងក្នុងឆ្នាំ ២០១៦ ទៅលើសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។

- បច្ចុប្បន្នភាពនៃស្ថានភាពជាក់ស្តែង ក្នុងឆ្នាំ២០១៧ ។
- ផែនការសកម្មភាពដែលស្នើឡើងដោយសហរដ្ឋអាមេរិក បន្ទាប់ពីបានវាយតម្លៃផ្តល់ចំណាត់ថ្នាក់លេខ២ លើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- ផែនការសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស របស់អាស៊ាន ។
- ទិសដៅសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧ ។

**ក.២.១.លទ្ធផលនៃការវាយតម្លៃផែនការសកម្មភាពជាតិពាក់កណ្តាលអាណត្តិ៖**

ផ្អែកលើការវាយតម្លៃផែនការសកម្មភាព (២០១៤-២០១៨) ពាក់កណ្តាលអាណត្តិ របស់អ្នកជំនាញវាយតម្លៃឯករាជ ដែលបានធ្វើឡើងនៅចុងឆ្នាំ២០១៦ បានរកឃើញថា៖

យន្តការជាតិឈ្មោះថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ថា គ.ជ.ប.ជ ដែលបង្កើតឡើងដោយ ព្រះរាជក្រឹត្យ លេខនស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ នៅតែមានតួនាទីសំខាន់ ក្នុងការប្រមូលផ្តុំកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប សម្រាប់ការឆ្លើយតបទៅនឹងបទល្មើសជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ។

«គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៖ គ.ជ.ប.ជ គឺជាយន្តការថ្នាក់ជាតិសម្រាប់ ដឹកនាំ សម្របសម្រួល ជំរុញ និងប្រមូលពត៌មានអំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ (NGOs) ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីសហការគ្នាប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ដែលមានលក្ខណៈតម្លាភាព គណនេយ្យភាព និងប្រសិទ្ធិភាពខ្ពស់ ក្នុងការឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ដើម្បីបង្ក្រាបអំពើជួញដូរមនុស្សគ្រប់រូបភាព ជាអាទិ៍មានការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរកុមារទារក ការជួញដូរសរីរាង្គ ...។ល។ »

យន្តការនេះ ដឹកនាំដោយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មានក្រសួងចំនួន ២១ និងអង្គភាពជំនាញចំនួនប្រាំជាសមាជិក គឺ៖

- **ក្រសួងចំនួន២១ មាន៖**

  (១)ក្រសួងមហាផ្ទៃ (២)ក្រសួងអប់រំយុវជននិងកីឡា (៣)ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (៤)ក្រសួងយុត្តិធម៌ (៥)ក្រសួងកិច្ចការនារី (៦)ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ (៧)ក្រសួងសុខាភិបាល (៨)ក្រសួងទេសចរណ៍ (៩)ទីស្តីការគណៈរដ្ឋមន្ត្រី (១០)ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ (១១)ក្រសួងការពារជាតិ (១២)ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (១៣)ក្រសួងផែនការ

(១៤)ក្រសួងព័ត៌មាន (១៥)ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (១៦) ក្រសួងអភិវឌ្ឍន៍ជនបទ (១៧)ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (១៨)ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១៩)ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (២០)ក្រសួងធម្មការ និងសាសនា (២១)ក្រសួងមុខងារសាធារណៈ ។

- **អង្គភាពជំនាញចំនួន៥៖**

  (១)អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ (២)កងរាជអាវុធហត្ថលើផ្ទៃប្រទេស (៣)អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ (៤)អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ (៥)នាយកដ្ឋានកិច្ចការព្រំដែននៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរៈភូមិន្ទ ។

- **គ.ជ.ប.ជ ចែកចេញជា ៦ក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន** តែងតាំងដោយសេចក្តីសម្រេច របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លេខ ០៩៤/១៤ សសរ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ គឺ៖

  (១) ក្រុមការងារបង្ការ ទប់ស្កាត់ ដឹកនាំដោយ រដ្ឋមន្រ្តីក្រសួងអប់រំ យុវជន និងកីឡា

  (២) ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយ រដ្ឋមន្រ្តីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

  (៣) ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយ អគ្គស្នងការនគរបាលជាតិ

  (៤) ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយ រដ្ឋមន្រ្តីក្រសួងយុត្តិធម៌

  (៥) ក្រុមការងារទំនាក់ទំនងអន្តរជាតិ ដឹកនាំដោយ រដ្ឋមន្រ្តីក្រសួងកិច្ចការនារី

  (៦) ក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយ រដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

- **គ.ជ.ប.ជ មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ** ដែលបង្កើតដោយអនុក្រឹត្យលេខ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ មានភារកិច្ចសំខាន់ក្នុងការសម្របសម្រួល ដឹកនាំ ជំរុញ កិច្ចសហប្រតិបត្តិការ អន្តរក្រសួង ស្ថាប័ន រួមទាំងដៃគូទាំងឡាយ ក្នុង និងក្រៅប្រទេស ដែលធ្វើការងារពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការអនុវត្តច្បាប់ ដើម្បីបង្ក្រាបបទល្មើស និងជនល្មើសដែលជួញដូរ និងកេងប្រវ័ញ្ច សង្គ្រោះ ផ្តល់យុត្តិធម៌ និងផ្តល់កិច្ចការពារដល់ជនរងគ្រោះ ទាំងស្រ្តី បុរស កុមារ ឲ្យមានប្រសិទ្ធភាព ។

- **គ.ជ.ប.ជ មានរចនាសម្ព័ន្ធដល់ថ្នាក់ក្រោមជាតិ** ដែលនៅតាមបណ្តារាជធានី-ខេត្ត មានតែងតាំងជាគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ/រ.ប.ជ) តាមសេចក្តីសម្រេចលេខ ០០១/១៤ សសរ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ។ គណៈកម្មាធិការនេះ ដឹកនាំដោយអភិបាល រាជធានី ឬខេត្ត មានសមាជិកជាប្រធានគ្រប់មន្ទីរ

ស្ថាប័នក្រោមឱវាទ និងអភិបាលគ្រប់ ក្រុង ស្រុក ខណ្ឌក្រោមចំណុះ ។ គ.ខ/រ.ប.ជ មានលេខាធិការដ្ឋាន ដឹកនាំដោយអភិបាលរងមួយរូប និងក្រុមការងារអន្តរមន្ទីរ ស្ថាប័នចំនួន៦ ដូចគ្នានឹងថ្នាក់ជាតិដែរ ។ លើសពីនេះទៅទៀត បណ្តាញការងារគណៈកម្មាធិការ មាននៅតាមបណ្តាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ថែមទៀត ។

- គ្រប់ក្រសួង ស្ថាប័ន អង្គភាព ជាសមាជិកគណៈកម្មាធិការជាតិ អគ្គលេខាធិការដ្ឋាន ក្រុមការងារអន្តរក្រសួង ស្ថាប័នទាំង៦ នៅថ្នាក់ជាតិ និងគ្រប់មន្ទីរ និងថ្នាក់ដឹកនាំរដ្ឋបាលគ្រប់ថ្នាក់នៃគណៈកម្មាធិការរាជធានី-ខេត្ត លេខាធិការដ្ឋាន ព្រមទាំងបណ្តាញការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ក្រោមជាតិទាំងអស់ សុទ្ធតែមានតួនាទី និងភារកិច្ចអនុវត្តផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងអស់គ្នាដូចនៅថ្នាក់ជាតិដែរ ។

**បញ្ហាប្រឈម និងចំណុចខ្វះចន្លោះដែលនៅសេសសល់៖**

*ក្នុងយុទ្ធសាស្រ្តទី១៖*

- ក្រសួងស្ថាប័នជាសមាជិកមួយចំនួនមិនបានធ្វើរបាយការណ៍បញ្ជាក់ពីភាពជាក់លាក់នៃកិច្ចសហការ និងលទ្ធផល ក្នុងសកម្មភាពប្រឆាំងការជួញដូរមនុស្ស គឺគ្រាន់តែរាយការណ៍ពីសកម្មភាពទូទៅរបស់ក្រសួង ស្ថាប័នតែប៉ុណ្ណោះ
- របាយការណ៍ពីបណ្តាក្រុមការងារអន្តរក្រសួង មិនប្រមូលផ្តុំ និងមិនទាន់ពេលវេលា
- ខ្វះសូចនាករជាក់លាក់តាមយុទ្ធសាស្រ្តនីមួយៗ សម្រាប់ការតាមដានត្រួតពិនិត្យ
- មិនមានយន្តការ និងឧបករណ៍ច្បាស់លាស់ សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពជាតិ និងតាមដានប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការ
- ខ្វះយន្តការ និងផែនការសម្រាប់ការអភិវឌ្ឍសមត្ថភាពមន្រ្តី និងអង្គភាព ស្ថាប័នអនុវត្តន៍
- ខ្វះកិច្ចសហការ និងគំនិតច្នៃប្រឌិត សម្រាប់សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងមុខសញ្ញារបស់ជំនាញនៃបណ្តាក្រសួងស្ថាប័ន ដែលឆ្លើយតបទៅនឹងយុទ្ធសាស្រ្តជាតិ
- ត្រូវការទម្រង់សាមញ្ញនៃរបាយការណ៍មួយឆ្លើយតបទៅនឹងយុទ្ធសាស្រ្តនិងសូចនាករដែលមានលក្ខណៈជាប្រព័ន្ធ និងអាចវាយតម្លៃបាន
    - គ.ខ.ប.ជ មួយចំនួន មិនទាន់មានផែនការសកម្មភាព
    - អនុក្រិត្យ ១៨៣ មិនទាន់បានកែលម្អ
    - មិនមានគោលនយោបាយគ្រប់គ្រងការធ្វើចំណាកស្រុកតាមរដូវកាល ។

***ក្នុងយុទ្ធសាស្ត្រទី២៖***

- មិនទាន់មានយុទ្ធសាស្ត្របង្ការ ទប់ស្កាត់ ដែលមានលក្ខណៈជាប្រព័ន្ធ
- មិនទាន់មានការវាយតម្លៃអំពីប្រសិទ្ធភាពកម្មវិធីបណ្តុះបណ្តាលជំនាញតាមបណ្តាស្ថាប័ន ឬអង្គការដៃគូនានា
- ខ្វះការស្រាវជ្រាវអំពីផលប៉ះពាល់នៃការផ្តល់ប្រាក់កម្ចីទាំងផ្លូវការនិងមិនផ្លូវការនិងថាតើវាបានជួយលើកកម្ពស់ជីវភាព ឬបង្កើនភាពងាយរងគ្រោះចំពោះការជួញដូរមនុស្ស?
- មិនមានរបាយការណ៍អំពីការប្រើប្រាស់មូលនិធិសមធម៌ សម្រាប់សេវាថែទាំសុខភាពដើម្បីកាត់បន្ថយភាពក្រីក្ររបស់ជនរងគ្រោះ
- មិនទាន់បានបញ្ចូលសកម្មភាពប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងផែនការសុវត្ថិភាពកុមារតាមវិស័យក្នុងផែនការសកម្មភាពនៃរាជធានីនិងខេត្ត
- មិនមានការសិក្សាស្រាវជ្រាវ ដើម្បីកំណត់ប្រព័ន្ធផ្ទេរប្រាក់ទាំងផ្លូវការ និងមិនផ្លូវការដែលកំពុងប្រើប្រាស់ដោយជនចំណាកស្រុក និងការវិនិយោគប្រាក់បញ្ញើដើម្បីបង្កើតអនុសាសន៍នានា សម្រាប់ការកែលម្អប្រសិទ្ធភាពនៃការប្រើប្រាស់ប្រាក់បញ្ញើដែលផ្តល់ប្រយោជន៍ដល់ជនចំណាកស្រុក ក្រុមគ្រួសារ និងសហគមន៍ ។

**ក្នុងយុទ្ធសាស្ត្រទី៣ : ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបនឹងការជួញដូរមនុស្ស**

- មានបទល្មើសថ្មី ហើយករណីចាស់ជាច្រើនមិនទាន់សម្រេចផ្តន្ទាទោស នៅឡើយ
- មុខសញ្ញាការងារមួយចំនួន ខ្វះថវិកាសម្រាប់អនុវត្តសកម្មភាពប្រឆាំងការជួញដូរមនុស្ស ជាពិសេសក្នុងប្រតិបត្តការស៊ើបអង្កេត និងបង្ក្រាប
- ខ្វះធនធានមនុស្សសម្រាប់កិច្ចការយុត្តិធម៌ ជាពិសេស ការបង្កើតអាជ្ញាធរកណ្តាល និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ក្នុងក្រសួងយុត្តិធម៌
- គោលការណ៍ណែនាំសម្រាប់ UIA មិនទាន់ត្រូវបានបង្កើត និងអនុម័ត
- មិនមានផលិតជាសៀវភៅរបាយការណ៍ ស្តីពីការសម្រេចចិត្តរបស់តុលាការលើករណីជួញដូរមនុស្ស
- ឯកសារ និងការវិភាគករណីនៃការជួញដូរមនុស្សដែលអនុវត្តដោយតុលាការរាជធានីខេត្ត មិនបានកើតឡើងជាលក្ខណៈប្រព័ន្ធទេ
- មិនមានសូចនាករជាតួលេខសម្រាប់លទ្ធផលនៃការផ្តន្ទាទោស
- មិនមានប្រព័ន្ធទិន្នន័យនៃការផ្តន្ទាទោស ដែលត្រូវបានចងក្រងជាឯកសារអេឡិកត្រូនិក ។

**ក្នុងយុទ្ធសាស្ត្រទី ៤ :**

- ក្រសួងសង្គមកិច្ចនៅតែខ្វះបុគ្គលិក ធនធានមនុស្សដែលមានសមត្ថភាព និងថវិកាដើម្បីធ្វើឲ្យសម្រេចបាននូវលទ្ធផលតាមការរំពឹងទុក

- មិនទាន់មានមណ្ឌលរបស់រដ្ឋាភិបាល សម្រាប់ការផ្តល់សេវាជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- មិនទាន់ផ្តល់នីតិសម្បទាដល់មណ្ឌលដែលទទួលថែទាំជំនួស របស់អង្គការមិនមែនរដ្ឋាភិបាល
- មិនទាន់បានធ្វើការស្រាវជ្រាវលើការជួញដូរមនុស្ស សម្រាប់គោលបំណងសុំទាននៅក្នុងប្រទេសប្រភព និងប្រទេសគោលដៅ ដើម្បីរកវិធីទប់ស្កាត់កុមារសុំទាន
- មិនទាន់មានផែនការតាមដាន និងវាយតម្លៃការអនុវត្តគោលការណ៍ណែនាំ ស្តីពីកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយដល់ជនរងគ្រោះនៃការជួញដូរមនុស្ស
- ទិន្នន័យនៃរបាយការណ៍ ស្តីពីកិច្ចការពារជនរងគ្រោះ នៅមានកម្រិត និងមិនមានសូចនាករច្បាស់លាស់
- មិនមានផែនការបង្ការ ទប់ស្កាត់ និងលើកកម្ពស់ការយល់ដឹង នៅតាមកន្លែងបណ្តុះបណ្តាល និងបន្តធ្វើជាមួយក្រុមជនរងគ្រោះតាមសហគមន៍ ។

**ក.២.២. ផ្តោតលើបច្ចុប្បន្នភាពនៃស្ថានភាព ឆ្នាំ២០១៧ និង២០១៨៖**

បញ្ហាគន្លឹះមួយចំនួន ដែលកើតមានក្នុងឆ្នាំ២០១៧ និងអាចអូសបន្លាយដល់ឆ្នាំ២០១៨ ហើយចាំបាច់ត្រូវរកដំណោះស្រាយតាមរយៈសកម្មភាពជាអាទិភាពមួយចំនួន ដូចខាងក្រោម ៖

<u>**ពាក់ព័ន្ធកម្លាំងពលកម្ម៖**</u>

១. ចំនួន និងបញ្ហាប្រឈមរបស់ពលករដែលបាននិងកំពុងធ្វើការនៅក្រៅប្រទេស (ជាពិសេសនៅប្រទេសថៃ និងនៅប្រទេសម៉ាឡេស៊ី)៖

- មានពលករសរុប ១.០៥០.០០០នាក់ ដែលបាន និងកំពុងធ្វើការក្នុងប្រទេសថៃ និងប្រមាណ ៥០.០០០នាក់ បាននិងកំពុងធ្វើការនៅម៉ាឡេស៊ី ដែលក្នុងនោះមានប្រមាណ ៣០% ដែលទៅដោយស្របច្បាប់ តាមរយៈអនុស្សរណៈនៃការយោគយល់គ្នា
- មួយចំនួនបានទទួលការ ផ្តល់ភាពស្របច្បាប់ក្នុងប្រទេសថៃ រួមមានការផ្តល់លិខិតឆ្លងដែន ការផ្តល់ប័ណ្ណអនុញ្ញាតស្នាក់នៅ ប័ណ្ណអនុញ្ញាតឲ្យធ្វើការងារ កិច្ចសន្យាការងារ ជាដើមក្រោមការព្រមព្រៀងរវាងរដ្ឋាភិបាលថៃ និងកម្ពុជា មុនពេលអនុវត្តច្បាប់រឹតបន្តឹងចំពោះពលករបរទេសខុសច្បាប់ តាមរាជបញ្ញត្តិ និងច្បាប់ការងារថៃ
- មួយចំនួនទៅដោយខុសច្បាប់ ត្រូវបានបង្ក្រាបក្នុងប្រទេសថៃ និងម៉ាឡេស៊ី និងត្រូវបានដាក់ទោសទណ្ឌ ឬបញ្ជូនត្រឡប់មកកម្ពុជាវិញ
- មួយចំនួនកំពុងរត់គេច ឬជួញដូរបន្ត
- មានពលករមួយចំនួនតាមបណ្តោយព្រំដែន ដែលត្រូវចេញចូលប្រចាំថ្ងៃ ។

២. ពលករដែលត្រូវបានបញ្ជូនត្រឡប់ ឬវិលត្រឡប់
- ដោយភាពរងគ្រោះ
- ដោយចប់ការងារ
- ដោយមានធុរៈបណ្ដោះអាសន្ន ...

៣. កម្លាំងពលកម្មដែលត្រៀមចេញ
- នៅតាមសហគមន៍
- នៅតាមព្រំដែន
- នៅតាមសាលារៀន ។

ពាក់ព័ន្ធផ្លូវភេទ៖
- ការរីកឡើងវិញនៃសេវាកំសាន្តសប្បាយដែលបង្កប់សេវាផ្លូវភេទ
- ការកើនឡើងនូវករណីរំលោភ ដែលបានរកឃើញ និងបង្ក្រាប
- ការពពោះជំនួស ដែលអាចឈានទៅដល់ការនាំទារកចេញដោយខុសច្បាប់ ឬការរត់ពន្ធ ឬការជួញដូរទារក
- ការនាំចេញដើម្បីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ ដែលនាំឲ្យមានការរំលោភបំពាន ។

ករណីពាក់ព័ន្ធដទៃទៀត៖
- ការល្បួង អូសទាញ ឬចាប់បង្ខំកុមារចេញពីអាណាព្យាបាល។ល។

បញ្ហាទាំងអស់នេះចាំបាច់ត្រូវលើកសកម្មភាពដោះស្រាយ ជាអាទិភាព ។

### ក.២.៣. សកម្មភាពស្នើឡើងដោយសហរដ្ឋអាមេរិក បន្ទាប់ពីការវាយតម្លៃប្រចាំឆ្នាំ ២០១៦-២០១៧៖

លទ្ធផលនៃការវាយតម្លៃរបស់សហរដ្ឋអាមេរិក សម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៦-២០១៧ គឺចំណាត់ថ្នាក់លេខ២ ។ ក្នុងនោះ ក្រុមអ្នកវាយតម្លៃបានធ្វើសំណូមពរឲ្យយកចិត្តទុកដាក់បន្តទៀតលើ៖

១. ការបង្កើនកិច្ចខិតខំប្រឹងប្រែងលើការស៊ើបអង្កេតយ៉ាងសកម្មនិងខ្ជាប់ខ្ជួន ការកាត់ទោស ការផ្ដន្ទាទោស ការដាក់ទណ្ឌកម្មលើជនល្មើសជួញដូរមនុស្ស និងជួញដូរផ្លូវភេទ (យុត្តិធម៌)

២. ការចេញបទដ្ឋានគតិយុត្តិ អនុញ្ញាតឲ្យប្រើបច្ចេកទេសធ្វើការស៊ើបអង្កេតសម្ងាត់ក្នុងការអនុវត្តច្បាប់ស្ដីពីការប្រឆាំងការជួញដូរមនុស្ស (យុត្តិធម៌ និងមហាផ្ទៃ)

៣. បង្កើនការប្រឹងប្រែងលើការស៊ើបអង្កេត និងផ្ដន្ទាទោសលើមន្ត្រីរដ្ឋាភិបាល ដែលឃុបឃិតក្នុងអំពើជួញដូរមនុស្ស (យុត្តិធម៌ និងមហាផ្ទៃ)

៤. ដាក់វិធានការត្រួតពិនិត្យឲ្យបានហ្មត់ចត់ និងជាប់ជាប្រចាំ ដើម្បីជំរុញការអនុវត្តឲ្យបានប្រសើរនូវការជ្រើសរើសពលករ ការដាក់ការងារឲ្យធ្វើ និងការការពារពលករដែលទៅធ្វើការក្រៅប្រទេស (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)

៥. ពង្រឹងការដាក់ទោសទណ្ឌលើក្រុមហ៊ុនដែលធ្វើខុសច្បាប់ក្នុងដំណើរការជ្រើសរើស ដូចជាការដាក់ឲ្យជាប់បំណុល ឃុំខ្លួនពលករក្នុងពេលបណ្តុះបណ្តាល និងជ្រើសរើសពលករក្រោម ១៨ឆ្នាំ (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ )

៦. ផ្សព្វផ្សាយដល់អាជ្ញាធរមានសមត្ថកិច្ចអនុវត្តច្បាប់ និងអ្នកធ្វើគោលនយោបាយ ដើម្បីឲ្យបានដឹងអំពីការកើនឡើងនៃចំនួននៃការជួញដូរបុរស ជាពិសេស ក្នុងឧស្សាហកម្មនេសាទ និងគួរផ្តល់សេវាសមស្របដល់ជនរងគ្រោះជាបុរស (គណៈកម្មាធិការគ្រប់ថ្នាក់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា)

៧. ពង្រីក ឬបន្លាយនីតិវិធីសម្រាប់ការផ្តល់របាយការណ៍ និងឆ្លើយតបទៅនឹងករណីដែលជនរងគ្រោះត្រូវបានរកឃើញក្នុងប្រទេស ដែលគ្មានស្ថានបេសកកម្មការទូតនៅទីនោះ (ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ)

៨. ពិនិត្យកែសម្រួលអនុក្រឹត្យលេខ១៩០ ឲ្យទូលំទូលាយ មានតម្លាភាព និងដែលមិនធ្វើឲ្យមានការបកស្រាយភ័ន្តច្រឡំ ដើម្បីការពារពលករទេសន្តរប្រវេសន៍ (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)

៩. បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើឲ្យដំណើរការក្តីក្នុងប្រព័ន្ធតុលាការ ផ្តល់ភាពជឿជាក់គ្រប់គ្រាន់ដែលជាសេចក្តីត្រូវការ និងផលប្រយោជន៍របស់ជនរងគ្រោះដោយការជួញដូរ (ក្រសួងយុត្តិធម៌ និងស្ថាប័នអយ្យការ)

១០. បង្កើតបទដ្ឋានគតិយុត្តសម្រាប់ការការពារសាក្សីជនរងគ្រោះ ជាពិសេសដោយការជួញដូរមនុស្ស (ក្រសួងយុត្តិធម៌)

១១. ពង្រីកកិច្ចខិតខំក្នុងការធ្វើកំណត់សម្គាល់ជនរងគ្រោះជាមុន ក្នុងចំណោមជនងាយរងគ្រោះ ដូចជាកុមារ ជនកម្ពុជាដែលត្រឡប់មកពីធ្វើការនៅប្រទេសផ្សេងទៀត (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)

១២. ផ្តល់ការបណ្តុះបណ្តាល អំពីពិធីសារសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានទូលំទូលាយទូទាំងប្រទេស (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)

១៣. លើកកម្ពស់ការបញ្ជូនជនរងគ្រោះពីរដ្ឋាភិបាល ទៅអង្គការ ដោយបង្កើនការឧបត្ថម្ភគាំទ្រ និងសេវា រួមទាំងជំនួយផ្នែកច្បាប់ ការគាំទ្រចិត្តសាស្ត្រសង្គម និងកម្មវិធីសមាហរណកម្ម (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)

១៤. បង្កើតនីតិវិធីក្នុងការជួយជនរងគ្រោះកម្ពុជា តាមរយៈស្ថានបេសកកម្មការទូតនៅក្រៅប្រទេស ដូចជាការដាក់ឲ្យមានអនុព័ន្ធការងារក្នុងប្រទេសដែលមានពលករកម្ពុជាច្រើន (ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ)

១៥. ធ្វើឲ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការអន្តរភ្នាក់ងារ និងសម្របសម្រួលកិច្ចសហការរវាងនគរបាល ជាមួយស្ថាប័នអយ្យការ និងមន្ត្រីរដ្ឋាភិបាលដទៃទៀត ក្នុងករណីជួញដូរមនុស្ស និងនីតិវិធីបញ្ជូនជនរងគ្រោះ (ក្រសួងយុត្តិធម៌ និងអគ្គស្នងការដ្ឋាននគរបាលជាតិ)

១៦. និងបន្តឲ្យប្រើប្រាស់យុទ្ធនាការសាធារណៈ ក្នុងគោលបំណងកាត់បន្ថយតម្រូវការស្ត្រី និងកុមារ ដើម្បីបម្រើផ្លូវភេទក្នុងវិស័យទេសចរណ៍ ទាំងបរទេស ទាំងជនកម្ពុជា (ក្រុមការ ងារអន្តរក្រសួង និងថ្នាក់ក្រោមជាតិ)។

**ក.២.៤. ផែនការសកម្មភាព** ASEAN

បញ្ហាប្រឈមៈ

១. ភាពអសកម្មៈ អំពើពុករលួយ គម្លាតសេដ្ឋកិច្ច និងភាពក្រីក្រ កម្រិតនៃការអភិវឌ្ឍ អស្ថេរភាពសេដ្ឋកិច្ច ប្រព័ន្ធ និងការអនុវត្តច្បាប់គ្មានប្រសិទ្ធភាព តម្រូវការផ្គត់ផ្គង់រាល់ទម្រង់ធ្វើអាជីវកម្ម ..បង្កឲ្យមានភាពងាយរងគ្រោះ ។

២. ប្រព័ន្ធច្បាប់ៈ ខ្វះដោយអន្លើ ជាពិសេសរវាងប្រទេសដែលពាក់ព័ន្ធ ការអនុវត្តមិនទាន់មានប្រសិទ្ធភាព ។

៣. លើកកំពស់សមត្ថភាពមន្ត្រីៈ សមត្ថភាព និងនីតិវិធី សម្រាប់មន្ត្រីជួរមុខ ដើម្បីឆាប់រកឃើញ ទប់ស្កាត់បម្លាស់ទីរបស់ជនរងគ្រោះទៅកាន់ប្រទេសគោលដៅ ។

៤. កំណត់អត្តសញ្ញាណៈ បែបបទ នីតិវិធីកំណត់អត្តសញ្ញាណជនល្មើស និងជនរងគ្រោះ ត្រូវធ្វើឲ្យបានត្រឹមត្រូវ និងផ្តល់កិច្ចការពារឲ្យសមស្រប ។

៥. កែលម្អការស៊ើបអង្កេតៈ ជំរុញការស៊ើបអង្កេតឲ្យទាន់ពេល រកឲ្យឃើញ និងផ្តន្ទាទោសឲ្យត្រឹមត្រូវតាមច្បាប់ ពិសេសទាក់ទងនឹងរឿងក្តីស្មុគស្មាញ ។

៦. ទំនាក់ទំនងៈ លើកកម្ពស់ទំនាក់ទំនង និងសម្របសម្រួលផ្ទាល់រវាង និងក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ច និងអន្តរជាតិ ។

៧. យន្តការៈ ដើម្បីអនុវត្តច្បាប់ ចាំបាច់ត្រូវបង្កើតយន្តការចាំបាច់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ។

## សកម្មភាពដែលគប្បីជំរុញអនុវត្តៈ

ក. ការបង្ការ-ទប់ស្កាត់

១. លើកកម្ពស់ការយល់ដឹង តាមរយៈការអប់រំមនុស្សគ្រប់ស្រទាប់ក្នុងសង្គម ឲ្យយល់ដឹង និងចូលរួមបង្ការ ទប់ស្កាត់ មានការចូលរួមពីប្រព័ន្ធផ្សព្វផ្សាយ NGOs និងផ្នែកឯកជន ស្តីពីអំពើជួញដូរមនុស្ស និងចូលរួមបង្ការទប់ស្កាត់ការពារ ជាពិសេសដល់ក្រុមជនដែលមានហានិភ័យខ្ពស់ ។

២. កសាង និងពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ មន្ត្រីអន្តោប្រវេសន៍ មន្ត្រីអប់រំ មន្ត្រីសង្គមកិច្ច មន្ត្រីការងារ និងមន្ត្រីពាក់ព័ន្ធទាំងឡាយ ដោយផ្តោតការយកចិត្តទុកដាក់លើសិទ្ធិមនុស្ស សិទ្ធិកុមារ និងយេនឌ័រ តាមស្ថានភាពជាក់ស្តែង ដោយជំរុញលើកទឹកចិត្តដល់កិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងផ្នែកពាក់ព័ន្ធ ។

៣. បង្កើតយន្តការដែលមានប្រសិទ្ធភាព ដើម្បីបង្ការ ទប់ស្កាត់បម្លាស់ទី របស់ពួកជួញដូរ និងជនរងគ្រោះ តាមរយៈការត្រួតពិនិត្យព្រំដែន ការចេញឯកសារអត្តសញ្ញាណ ឯកសារធ្វើដំណើរ បង្ការទប់ស្កាត់ការក្លែងបន្លំ ការក្លែងក្លាយ ឬប្រើឯកសារអត្តសញ្ញាណ និងឯកសារទុច្ចរិត ។

៤. បង្កើនកិច្ចសហការក្នុងការពិនិត្យ និងពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ឆ្លងដែន ចែករំលែកព័ត៌មាន (សម្ងាត់ ឬចំហ) រវាងសមត្ថកិច្ច និងប្រទេសពាក់ព័ន្ធ សំដៅបន្ទុចបង្អាក់ប្រតិបត្តិការរបស់ពួកជនជួញដូរ ។

៥. អនុវត្តច្បាប់ការងារ តាមរយៈយន្តការដែលសមស្របនឹងបណ្តាយន្តការផ្សេងទៀតដើម្បីលើកស្ទួយ ការពារផលប្រយោជន៍ពលករ កាត់បន្ថយហានិភ័យ ។

៦. សម្របសម្រួល បង្កើត និងជំរុញអនុវត្តផែនការសកម្មភាពជាតិ ជំរុញការអនុវត្ត ដោយផ្តល់អាទិភាពលើសកម្មភាពជាគន្លឹះ ផ្អែកលើគោលនយោបាយ កម្មវិធីសំខាន់ៗ ដែលលើកក្នុងផែនការ និងតាមដានការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ។

៧. គាំទ្រការសិក្សាស្រាវជ្រាវ ក្រោមប្រធានបទពាក់ព័ន្ធ (អាស៊ាន) ប្រមូលទិន្នន័យ វិភាគចរិតលក្ខណៈ វិសាលភាព ថ្នាក់ជាតិ តំបន់ ។

៨. កសាងមូលដ្ឋានទិន្នន័យ ដោយប្រមូល ចងក្រងទិន្នន័យថ្នាក់ជាតិ មានវិធីសាស្ត្រផ្លាស់ប្តូរទិន្នន័យ (អាស៊ាន) ឈានទៅបង្កើតទិន្នដ្ឋានអាស៊ាន ។

៩. ប្រើប្រាស់ និងពង្រឹងការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិ ដែលកំណត់អត្តសញ្ញាណ និងជួយជនរងគ្រោះ មិនរើសអើង រកឃើញ បង្ការ ទប់ស្កាត់ កាត់បន្ថយ អតិបរមា ។

១០. គាំទ្រសកម្មភាពបង្ការទប់ស្កាត់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ផ្តោតលើការទប់ស្កាត់ទាំងតម្រូវការ ការផ្គត់ផ្គង់ ដែលជំរុញឲ្យមានអំពើជួញដូរមនុស្ស ។

១១. រិះរកយុទ្ធសាស្ត្រ និងយុទ្ធវិធីទប់ស្កាត់ និងលុបបំបាត់ការជួញដូរមនុស្សឆ្លងដែនប្រកប ដោយកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសប្រភព និងប្រទេសគោលដៅ ។

១២. ពង្រឹងវិធានការបង្ការ ទប់ស្កាត់តម្រូវការរបស់ជនល្មើស នៃរាល់ទម្រង់កេងប្រវ័ញ្ច និង ការធ្វើអាជីវកម្មលើមនុស្ស ការពារជនរងគ្រោះ ដើម្បីកុំឲ្យរងគ្រោះម្តងហើយម្តងទៀត ។

**ខ. កិច្ចការពារជនរងគ្រោះ**

១. លើកកម្ពស់ការគោរព និងការពារសិទ្ធិមនុស្សជាពិសេស សិទ្ធិជនរងគ្រោះ ដោយបំពេញ បន្ថែមនូវវិធានការដ៏មានប្រសិទ្ធភាព ក្នុងការការពារ និងជួយជនរងគ្រោះ ។

២. ផ្តល់ការថែទាំ គាំទ្រ និងអភិវឌ្ឍដល់ជនរងគ្រោះគ្រប់ភេទ គ្រប់វ័យ ។

៣. កំណត់អត្តសញ្ញាណ (តាមអនុសញ្ញាអាស៊ាន) កសាង និងអនុវត្តលិខិតុបករណ៍ជាតិ អន្តរជាតិពាក់ព័ន្ធ ដើម្បីឲ្យជនរងគ្រោះទទួលបានទទួលសេវាសុខភាព សេវាបង្ការ ការព្យាបាល ការថែទាំ និងព្យាបាលជំងឺ (ពិសេសជំងឺឆ្លង) សិក្សាហេតុផល និងការប៉ះ ពាល់រយៈពេលវែង ។

៤. អនុលោមតាមច្បាប់ នូវរាល់បទបញ្ញត្តិ បទបញ្ជា និងបណ្តាគោលនយោបាយផ្ទៃក្នុង និងផ្អែកតាមករណីសមស្របនានា (*មិនដាក់ឲ្យជនរងគ្រោះទទួលខុសត្រូវខាងផ្នែកព្រហ្ម ទណ្ឌ ឬរដ្ឋបាលដោយសារតែអំពើខុសច្បាប់ ដែលពួកគេបានប្រព្រឹត្តក្នុងអំឡុងពេល ដែលរងគ្រោះដោយអំពើជួញដូរមនុស្សឡើយ*) ។

៥. ផ្តល់លទ្ធភាព ជួយឧបត្ថម្ភ ផ្តល់សេវាកម្មនានាដល់កុមារ ស្ត្រី សម្រាប់ស្តារឡើងវិញ ផ្នែករាងកាយ ចិត្តសាស្ត្រសង្គម និងស្តារនីតិសម្បទា ដោយសហការជាមួយផ្នែក ពាក់ព័ន្ធ បង្កើតបណ្តាញផ្តល់សេវា ផ្តល់ការថែទាំវេជ្ជសាស្ត្រ ការពិគ្រោះយោបល់ ការអប់រំ ឱកាសបណ្តុះបណ្តាល ជំនួយផ្នែកច្បាប់ និងសេវាបកប្រែជាដើម ។

៦. ប្រើប្រាស់ប្រព័ន្ធ៖ កសាងប្រព័ន្ធការងារ ដែលធានាដល់ដំណើរការចាត់ចែងជនរង គ្រោះទាក់ទងនឹងការសង្គ្រោះ ការការពារ រួមជាមួយសហគមន៍ ។

៧. ធានាប្រព័ន្ធច្បាប់៖ បញ្ចូលនូវវិធានការនានា (រដ្ឋបាល) ផ្តល់ព័ត៌មានដល់ជនរងគ្រោះ (តាមភាសាជនរងគ្រោះ) ស្តីពីសិទ្ធិ នីតិវិធីតុលាការអាជ្ញាធរពាក់ព័ន្ធ បង្កលក្ខណៈ ដាក់ បញ្ចូលក្តីកង្វល់ ដោយគិតគូរតាមដំណាក់កាលនីតិវិធីរឿងក្តី ប្រឆាំងជនល្មើសដោយ ពុំមានព្យសនកម្មដល់សិទ្ធិការពារក្តី (ច្បាប់ ACTIP) ។

៨. តួនាទីសង្គមស៊ីវិល៖ គាំទ្រការផ្តល់ជំនួយរបស់អង្គការសង្គមស៊ីវិល ដែលជួយជនរង គ្រោះ ស្វែងរកសំណង សម្រួលការថែទាំ ផ្តល់សេវាសហការជាមួយសមត្ថកិច្ច។

**គ. ការផ្តន្ទាទោស ៖**

ការចាត់ទុកជាអំពើល្មើសច្បាប់ ការផ្តន្ទាទោស ការអនុវត្តច្បាប់ និងការវិនិច្ឆ័យទោស៖

១. ការចាត់ទុកជាអំពើល្មើសច្បាប់ ៖ មានចែងក្នុងច្បាប់ប្រទេស និងច្បាប់អន្តរជាតិ ។
២. ការផន្ទាទោស៖ ជំរុញ និងលើកកម្ពស់ការផ្តន្ទាទោសជនល្មើសឲ្យបានត្រឹមត្រូវតាមនីតិវិធី និងច្បាប់កំណត់ ។
៣. ជំរុញការអនុវត្តច្បាប់ តាមរយៈការផ្សព្វផ្សាយពង្រីកការយល់ដឹង ធ្វើការតាមដានស៊ើបអង្កេត ឈានទៅបង្ក្រាប កសាងសំណុំរឿង ប្រមូលភស្តុតាង ដើម្បីដាក់បន្ទុកជនល្មើសតាមច្បាប់ ។
៤. ការវិនិច្ឆ័យទោស ៖ ជំរុញការផ្តន្ទាទោស ។

**ឃ. ការអនុវត្តច្បាប់ ផ្តន្ទាទោស វិនិច្ឆ័យទោស**

១. កសាងសមត្ថភាព ៖ ពង្រឹងសមត្ថភាពឲ្យបានខ្លាំងក្លាដល់មន្ត្រីអនុវត្តច្បាប់ ព្រះរាជអាជ្ញា ចៅក្រម មន្ត្រីអន្តោប្រវេសន៍ មន្ត្រីការបរទេស មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីសង្គមកិច្ច មន្ត្រីក្រសួងការងារ មន្ត្រីសង្គមកិច្ច និងមន្ត្រីពាក់ព័ន្ធ។
២. បង្កើតព្រះរាជអាជ្ញាឯកទេស៖ ត្រូវការចាំបាច់ដើម្បីដោះស្រាយតែរឿងក្តីជួញដូរមនុស្ស។
៣. បង្កើតយន្តការឯកទេស ៖ ជាយន្តការឯកទេសក្នុងក្របខ័ណ្ឌជាតិ អន្តរជាតិ ។
៤. បង្កើតវិធីសាស្រ្តស៊ើបអង្កេតបុរេសកម្ម៖ តាមកាលៈទេសៈសមស្រប អនុវត្តការឃ្លាំមើល បណ្តាវិធានការបុរេសកម្មផ្សេងទៀត ដើម្បីប្រមូលភស្តុតាង បើកករណីនាំដល់ការផ្តន្ទាទោស ទោះបីគ្មានសក្ខីកម្មជនរងគ្រោះក៏ដោយ ។
៥. ពិនិត្យលទ្ធភាពច្បាប់កំណត់លើកលែងការបង់ថ្លៃ ដើម្បីសម្រាលដល់ការចូលស្នាក់នៅបណ្តោះអាសន្នដល់ជនរងគ្រោះ ក្នុងគោលបំណងផ្តល់សក្ខីកម្ម ឬសហការក្នុងដំណើរការផ្តន្ទាទោស ។
៦. ការផ្តន្ទាទោសជនល្មើស គប្បីដាក់បញ្ចូលគ្រប់ទម្រង់នៃអំពើធ្វើអាជីវកម្មលើមនុស្ស ដោយអនុម័តច្បាប់ និងពង្រឹងការអនុវត្ត ។
៧. ប្រឆាំងឧក្រិដ្ឋជនឆ្លងដែន ដោយផ្តន្ទាទោសជនល្មើសដោយយោងតាមច្បាប់របស់ប្រទេស ។
៨. សម្របសម្រួលកិច្ចសហប្រតិបត្តិការនៅថ្នាក់ជាតិ និងអន្តរជាតិ ក្នុងរឿងក្តីអាចជាប់ទាក់ទងអំពើជួញដូរដូចជា ការសំអាតប្រាក់ អំពើពុករលួយ ការរត់ពន្ធទេសន្តរប្រវេសន៍ និងគ្រប់ទម្រង់ឧក្រិដ្ឋកម្មដែលមានការចាត់តាំង ។
៩. វិធានការជំនួយផ្លូវច្បាប់ ដែលអាចមានលទ្ធភាព ជំរុញការផ្តន្ទាទោសដែលអាចធ្វើទៅបានក្នុងការជួយគ្នាក្នុងដំណើរការក្តី ដើម្បីជំរុញការផ្តន្ទាទោស ដាក់ទោស (គិតទាំងសន្ធិសញ្ញាអាស៊ាន ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ និងកិច្ចព្រមព្រៀងទ្វេភាគីនានា) ។

១០. ចែករំលែកព័ត៌មាន ដើម្បីលើកទឹកចិត្ត និងជំរុញដំណើរការស៊ើបអង្កេតបង្កើតក្រុមឯកទេស ប្រព្រឹត្តរួមគ្នា ពន្លឿនការស៊ើបអង្កេត ផ្តន្ទាទោសរឿងក្តីធ្ងន់ធ្ងរ ឬមានស្ថានទម្ងន់ទោស (ថ្នាក់តំបន់) ។

១១. ផ្តន្ទាទោសមន្ត្រីពុករលួយ និងមន្ត្រីជួយសម្រួលបិទបាំងអំពើជួញដូរ ដោយគ្មានការអត់ឱន ឬលើកលែង ។

១២. យន្តការការពារ គប្បីអនុវត្តប្រកបដោយប្រសិទ្ធភាពសម្រាប់សាក្សីនៃអំពើជួញដូរ តាមលទ្ធភាពដែលអាចធ្វើទៅបាន ។

១៣. ការទទួលខុសត្រូវ របស់ជនល្មើសនៅក្នុងអំពើជួញដូរត្រូវតែធ្វើឡើងសមស្រប ទាំងនីតិបុគ្គល (ACTIP) ។

១៤. បង្កើនកិច្ចស៊ើបអង្កេត៖ ពង្រឹងបច្ចេកទេស មធ្យោបាយប្រើប្រាស់លក្ខណៈជាប្រព័ន្ធក្នុងការរឹបអូសទ្រព្យសម្បត្តិ ក្នុងបំណងដកហូតជាយថាហេតុ ធានាការដាក់ទោសសមាមាត្រទៅនឹងចរិតធ្ងន់ធ្ងរនៃបទល្មើស ។

ង. កិច្ចសហប្រតិបត្តិការ សម្របសម្រួល

១. បង្កើនកិច្ចសហប្រតិបត្តិការជាតិ ប្រទេសពាក់ព័ន្ធជាអន្តរជាតិ អង្គការក្នុងស្រុក និងអន្តរជាតិ សំដៅពង្រឹងសមត្ថភាព អនុវត្តដោយប្រសិទ្ធភាព ។

២. កែលម្អការកសាងសមត្ថភាពគ្រប់ផ្នែក នេះជាសមាសភាគមួយសំខាន់ ។

៣. បង្កើនកិច្ចសហការ ដោយពង្រឹងកិច្ចប្រតិបត្តិការជាតិ អន្តរជាតិ (អាស៊ាន) ទ្វេភាគី ពហុភាគី និងបង្កើតក្រុមស៊ើបអង្កេតរួមគ្នា ។

៤. ចាត់តាំងជនបង្គោល ដើម្បីទំនាក់ទំនង ចែករំលែកទិន្នន័យ ផ្លាស់ប្តូរព័ត៌មាន ពង្រឹងគោល នយោបាយ កម្មវិធី បង្ការ ទប់ស្កាត់ និងការពារជនរងគ្រោះ ។

- សម្របសម្រួលក្នុងចំណោមស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ផ្នែកឯកជន ប្រព័ន្ធផ្សព្វផ្សាយ..
- បង្កើន បន្តកសាងគោលការណ៍ដឹកនាំ ផ្អែកតាមគោលការណ៍ជាតិ ទ្វេភាគី ពង្រឹងភាពជាដៃគូ...

៥. ប្រើប្រាស់កិច្ចសហប្រតិបត្តិការអន្តរជាតិ បទបញ្ញត្តិ សន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងរឿងក្តីព្រហ្មទណ្ឌ (អាស៊ាន) បង្កើនទំនុកចិត្តដើម្បីធានាដល់ការស៊ើបអង្កេត និងដាក់ទោស។

៦. ប្រើប្រាស់យន្តការអន្តរជាតិ ដូចជា Interpol និងបណ្តាទិន្នដ្ឋាន Interpol ។

៧. កិច្ចសហការតំបន់អាស៊ាន រវាងក្រុមការងារទទួលបន្ទុកចំណុះឧត្តមមន្ត្រីអាស៊ាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន និងកិច្ចប្រជុំប្រធានឯកទេសនិងពិចារណាដល់ការពាក់ព័ន្ធផ្សេងទៀត។

៨. ពង្រឹងការកសាងសមត្ថភាព ដោយកែលម្អការរៀបចំទទួលសំណើ រៀបចំជំនួយផ្នែកច្បាប់ បត្យាប័ន អនុវត្តច្បាប់ឆ្លងដែន ។

៩. ផ្តល់ប្រយោជន៍ រួមគ្នាជាមួយដៃគូជាតិ អន្តរជាតិ តំបន់ អនុតំបន់ ក្នុងការផ្តល់បច្ចេកទេស មូលនិធិប្រកបដោយនិរន្តរភាព ។

ច. បន្តអនុវត្ត និងពិនិត្យឡើងវិញ :

១. ព្យាយាមរួមបញ្ចូលកម្មវិធី និងសកម្មភាពពាក់ព័ន្ធទៅក្នុងផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អាស៊ាន ទៅក្នុងផែនការសកម្មភាពជាតិ ដើម្បីធានាភាពជោគជ័យ ។

២. យន្តការ SOMTC ដោយមានការគាំទ្រពីក្រុមការងារទទួលបន្ទុកអំពើជួញដូរមនុស្សរបស់ SOMTC ត្រូវមើលការខុសត្រូវលើការអនុវត្តសកម្មភាពនេះ ។

# ខ. ផែនការសកម្មភាពជាតិប្រឆាំងនឹងអំពើជួញដូរមនុស្ស សម្រាប់អនុវត្ត ក្នុងឆ្នាំ២០១៤ និង២០១៨

## ខ.១. ទស្សនៈវិស័យ

*"ព្រះរាជាណាចក្រកម្ពុជាជាសង្គមមួយប្រកបដោយសន្តិភាព សមភាព និងការអភិវឌ្ឍ និងមានការការពារប្រជាពលរដ្ឋពីរាល់ទម្រង់នៃអំពើជួញដូរ និងការធ្វើអាជីវកម្មលើមនុស្ស" ។*

## ខ.២. ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ផែនការសកម្មភាពជាតិប្រឆាំងនឹងការជួញដូរមនុស្ស (ឆ្នាំ ២០១៤-២០១៨)

លទ្ធផលនៃការវាយតម្លៃផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០១៤-២០១៨) ពាក់កណ្តាលអាណត្តិទី១ គឺជាម៉ែត្រវាស់ និងជាមូលដ្ឋានសម្រាប់ការរៀបចំសកម្មភាព ឆ្នាំ២០១៧-២០១៨ ។ ក្របខណ្ឌយុទ្ធសាស្ត្រនេះគឺជាជំហានដំបូងដ៏សំខាន់មួយក្នុងដំណើរការយុទ្ធសាស្ត្រទូលំទូលាយ ដែលបង្ហាញនូវធាតុផ្សំនៃយុទ្ធសាស្ត្រ សម្រាប់ផែនការសកម្មភាពជាតិប្រឆាំងនឹងអំពើជួញដូរមនុស្ស ឆ្នាំ២០១៤-២០១៨ ដែលបានធានាដល់និរន្តរភាពនៃយន្តការ ដំណើរការ និងអន្តរាគមន៍ដែលមានការឯកភាពគ្នា និងដើរតួនាទីជាមូលដ្ឋានសម្រាប់ការកំណត់អាទិភាពជាយុទ្ធសាស្ត្រទិសដៅ និងអន្តរាគមន៍ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទក្នុងប្រទេសកម្ពុជា និងលើពលរដ្ឋកម្ពុជា នៅក្រៅប្រទេស ជាពិសេសលើស្ត្រី និងកុមារ ឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ។

ផែនការសកម្មភាពជាតិនេះ បានផ្តោតការពិចារណា និងដាក់បញ្ចូលផងដែរ អំពីទស្សនៈ និងការអនុវត្តរបស់សង្គមស៊ីវិល និងជនរងគ្រោះក្នុងបទឧក្រិដ្ឋនៃអំពើជួញដូរមនុស្ស ការរត់ពន្ធ និងការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដើម្បីឲ្យមានលក្ខណៈឆ្លើយតបទូលំទូលាយ ។

## ខ.៣. គុណតម្លៃស្នូលនៃផែនការសកម្មភាពជាតិ

✓ **ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលលើផែនការសកម្មភាពជាតិ**

រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសកម្មភាពអាទិភាពមួយដែលចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ និងជំរុញសកម្មភាព ។ ក្នុងការកែសម្រួលឡើងវិញ សម្រាប់សកម្មភាពពាក់កណ្តាលអាណត្តិនៃផែនការ ២០១៧-២០១៨ នេះ គឺដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត ផ្អែកលើបច្ចុប្បន្នភាពនៃបញ្ហាកាត់បន្ថយចំណាយដែលឲ្យប្រយោជន៍ និងឆ្លើយតបឲ្យចំទិសដៅទៅនឹងបញ្ហាដែលបាននិងកំពុងតែឈានទៅរកស្ថានភាពដែលកាន់តែពិបាក បើខ្វះការទប់ស្កាត់ ការពារ និងគ្រប់គ្រងល្អ ។ នេះគឺជាកិច្ចប្រឹងប្រែងប្រកបដោយការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ដោយមានការចូលរួមគាំទ្រ និងសហការយ៉ាងសកម្មពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ដទៃទៀតជាច្រើន ។ រាជរដ្ឋាភិបាលក៏មានភារកិច្ចដោះស្រាយកំណើននៃតម្រូវការធនធានហិរញ្ញវត្ថុ ដើម្បីអនុវត្តផែនការសកម្មភាពជាតិនេះ គួបផ្សំនឹងការចូលរួមពីដៃគូពាក់ព័ន្ធទាំងឡាយ ដើម្បីធានាថាលេខាធិការដ្ឋាន និងជំនាញពាក់ព័ន្ធគ្រប់ថ្នាក់មានលទ្ធភាពអនុវត្តភារកិច្ច និងអាចជំរុញឲ្យយុទ្ធសាស្ត្រ និងសកម្មភាពទាំងឡាយអនុវត្តបានតាមការគ្រោងទុក ។

✓ **<u>គោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន</u>**

រាជរដ្ឋាភិបាល បន្តប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារ និងគោរពសិទ្ធិ លើកកម្ពស់សុខុមាលភាព សុវត្ថិភាពរបស់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេសសិទ្ធិជនរងគ្រោះ ឬជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាស្នូលនៃកិច្ចប្រឹងប្រែងទាំងឡាយក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានការពារសុវត្ថិភាព ពង្រីកលទ្ធភាពក្នុងការទទួលបានព័ត៌មាន និងការផ្តល់នូវសេវាសង្គម រួមទាំងការគាំទ្រផ្លូវចិត្ត ជំនួយផ្នែកច្បាប់ ក៏ដូចជាជំនួយគាំទ្រផ្នែកសេដ្ឋកិច្ច ជំនាញ មុខរបរ និងឯកសារសម្រាប់គាំទ្រដល់ការសមាហរណកម្មរយៈពេលវែង ។

✓ **<u>កម្មវិធីផ្អែកលើគោលការណ៍យេនឌ័រជាមូលដ្ឋាន</u>**

បន្តអនុវត្ត ដោយលើកម្ពស់ការផ្តល់សេវាផ្អែកលើតម្រូវការយេនឌ័រ និងវ័យរបស់ក្រុមគោលដៅ ។ អំពើជួញដូរមនុស្ស និងទម្រង់ផ្សេងៗទៀតនៃអំពើហិង្សាលើយេនឌ័រ ត្រូវបានចាត់ទុកថា ជាបញ្ហាមួយដែលមានការវិវត្តន៍ និងជាការរំលោភបំពានលើសិទ្ធិមនុស្ស ដែលសហគមន៍ និងសង្គមត្រូវបន្តដោះស្រាយ ។

✓ **<u>មានការចូលរួមដោយសកម្មពីសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ</u>**

គណៈកម្មាធិការជាតិទទួលស្គាល់ថា អង្គការសង្គមស៊ីវិល នៅតែមានសក្តានុពលអាចជួយធ្វើឲ្យមានភាពប្រសើរឡើងនូវអន្តរាគមន៍ពាក់ព័ន្ធនឹងការបង្ការ ការការពារ និងការផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ យុត្តិធម៌ផ្អែកព្រហ្មទណ្ឌ សេវាច្បាប់ និងចិត្តសាស្ត្រ ក៏ដូចជា សេវាអនុវត្តច្បាប់សម្រាប់ជនរងគ្រោះនៃការធ្វើអាជីវកម្ម និងការរំលោភបំពាន ។ អង្គការដៃគូដែលមានឯកទេស នៅតែមានតួនាទីធ្វើជាដៃគូក្នុងការជួយកសាងសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ ឬក្នុងការផ្តល់សេវាសមាហរណកម្មជនរងគ្រោះទៅក្នុងសង្គមវិញ ហើយនឹងត្រូវបានទទួលនីតិសម្បទាជាអង្គការដែលមានសិទ្ធិ និងករណីយកិច្ចផ្តល់ការថែទាំជំនួសក្នុងសហគមន៍ ។ ព្រមជាមួយនេះ អ្នកផ្តល់សេវាគួរតែទទួលបានការប្រឹក្សាជាទៀងទាត់ពីក្រសួងពាក់ព័ន្ធ ដើម្បីទទួលបានព័ត៌មាន និងដឹកនាំការអនុវត្តសកម្មភាពនៃផែនការសកម្មភាព ដើម្បីឲ្យជនរងគ្រោះទទួលបានផលប្រយោជន៍បានច្រើនបំផុត ។

✓ **<u>សហប្រតិបត្តិការជាពហុវិស័យ និងភាពជាដៃគូ</u>**

គណៈកម្មាធិការជាតិ លើកទឹកចិត្តចំពោះកិច្ចសហការ ការសម្របសម្រួល និងភាពជាដៃគូនៅគ្រប់កម្រិត។ ស្ថាប័នរដ្ឋាភិបាលនឹងទទួលបានការសម្របសម្រួល និងបង្កើតភាពជាដៃគូ ជាមួយភាគីពាក់ព័ន្ធចម្រុះ ដូចជា សាស្ត្រាចារ្យ/អង្គការសិក្សាស្រាវជ្រាវ ក្រុមតស៊ូមតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ន ជំនឿសាសនា វិស័យឯកជន ម្ចាស់ជំនួយទ្វេភាគី និងពហុភាគីផ្សេងទៀត ទាំងនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីមានកិច្ចប្រតិបត្តិការល្អបំផុតសម្រាប់ជាយុទ្ធវិធីគ្រប់ជ្រុងជ្រោយពហុវិស័យក្នុងការអនុវត្តយុទ្ធសាស្ត្រទាំងបួន និងសកម្មភាពនៃផែនការដែលមានលទ្ធផល។ ផែនការសកម្មភាពជាតិ គាំទ្រដល់ការបង្កើតយន្តការ និងប្រព័ន្ធបញ្ជូនថ្នាក់ជាតិដែលមានប្រសិទ្ធភាព ដើម្បីពង្រឹងសេវាការពារជនរងគ្រោះដោយអំពើជួញដូរ ការធ្វើអាជីវកម្មពលកម្ម និងផ្លូវភេទ និងជនងាយរងគ្រោះដទៃទៀត ។

ប្រព័ន្ធនេះទាមទារឲ្យមានការបង្ការការកើតមានឡើងនូវអំពើហិង្សាគ្រប់រូបភាព និងការការពារជនរងគ្រោះ និងជនងាយរងគ្រោះគ្រប់តំណាក់កាលនៃកិច្ចអន្តរាគមន៍។ មិនតែប៉ុណ្ណោះ ផែនការសកម្មភាពជាតិគាំទ្រដល់ការពង្រឹងសមត្ថភាព ការផ្លាស់ប្តូរ

ឥរិយាបទដែលមិនសមរម្យ អន់ថយ និងរបៀបរបបការងារដែលមិនមានគុណភាព «*ឲ្យទៅជារបត់សង្គមមួយដែលប្រកបដោយវិន័យ សីលធម៌ល្អ ការគោរព និងការទទួលខុសត្រូវ*»។ អន្តរាគមន៍ជាពហុវិស័យសម្រាប់ការពង្រឹងប្រសិទ្ធភាពនៃសកម្មភាពបង្ការ ទប់ស្កាត់បទល្មើសបានទាន់ពេល កាត់បន្ថយភាពរងគ្រោះក្នុងសង្គម ព្រមទាំងគាំទ្រភាពជាដៃគូរវាងស្ថាប័នរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីបានចូលរួមចំណែកក្នុងការអនុវត្តផែនការសកម្មភាពជាផ្លូវការ និងប្រកបដោយនិរន្តភាព ។

- ✓ **ការត្រួតពិនិត្យ វាយតម្លៃជាប្រព័ន្ធ និងមាននិរន្តរភាព**

ការត្រួតពិនិត្យ និងវាយតម្លៃ គឺជាសមាសធាតុសំខាន់មួយនៃផែនការសកម្មភាពជាតិ។ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរឹងមាំមួនឹងត្រូវបានបង្កើតឡើង សម្រាប់កំណត់អំពីបរិមាណ និងគុណភាពនៃការអនុវត្ត ឆ្លើយតបទៅនឹងភាពចាំបាច់នៃតម្រូវការ ដោយផ្អែកលើសូចនាករសម្រាប់វាស់ស្ទង់ផលប៉ះពាល់ សមិទ្ធផល និងមេរៀនជាបទពិសោធន៍។

## ខ.៤. គោលដៅរួម

ផែនការសកម្មភាពជាតិប្រឆាំងអំពើជួញដូរមនុស្សរយៈពេល៥ឆ្នាំ តំណាក់កាលទី២ ឆ្នាំ២០១៤-២០១៨ **មានគោលដៅ** ***បន្តលើកកម្ពស់រាល់កិច្ចខិតខំប្រឹងប្រែងក្នុងសង្គមក្នុងការលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដែលកើតមាននៅក្នុងប្រទេសកម្ពុជា និងទៅលើប្រជាជនកម្ពុជាទោះជានៅទីណាក៏ដោយ ។***

ផែនការសកម្មភាពជាតិប្រឆាំងអំពើជួញដូរមនុស្ស លើកកម្ពស់សាមគ្គីភាព និងភាពជាដៃគូរវាងសហគមន៍ជាតិ និងអន្តរជាតិ និងមានគោលបំណងធានាឲ្យមានការអនុវត្តច្បាប់ដែលផ្តន្ទាទោសចំពោះបទឧក្រិដ្ឋបែបនេះ ដើម្បីយុត្តិធម៌សង្គម ជាពិសេសស្ត្រី បុរស កុមារី និងកុមារាទាំងអស់ដែលរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## ខ.៥. យុទ្ធសាស្ត្រនៃផែនការសកម្មភាពជាតិ

ដើម្បីសម្រេចបាននូវទស្សនៈវិស័យ ក្របខណ្ឌយុទ្ធសាស្ត្រ និងគោលដៅដែលកំណត់ក្នុងផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតំណាក់កាលទី២សម្រាប់អនុវត្តក្នុងឆ្នាំ២០១៤-២០១៨ ចាំបាច់ត្រូវបន្តជំរុញអនុវត្តយុទ្ធសាស្ត្រទាំងបួន ដែលបានកំណត់ក្នុងផែនការប្រាំឆ្នាំកន្លងមក គឺ ៖

១. លើកកម្ពស់ការអនុវត្តច្បាប់ គោលនយោបាយ និង កិច្ចសហប្រតិបត្តិការ

២. លើកកម្ពស់បង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស

៣. លើកកម្ពស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

៤. បង្កើនកិច្ចការពារជនរងគ្រោះជាពិសេសស្ត្រី និងកុមារ ។

## ខ.៤.១. យុទ្ធសាស្ត្រទី១ ៖ លើកកម្ពស់ការអនុវត្ត ច្បាប់ គោលនយោបាយ និង កិច្ចសហប្រតិបត្តិការ

**លទ្ធផលរំពឹងទុក ៖**

១. លើកកម្ពស់ការយល់ដឹង និងការប្រើប្រាស់លិខិតុបករណ៍ និងបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនៅថ្នាក់ជាតិ និងអន្តរជាតិ សម្រាប់ការបង្ការ ទប់ស្កាត់ និង លុបបំបាត់បទល្មើសជួញដូរមនុស្ស និងរាល់ទម្រង់ដែលពាក់ព័ន្ធ (ជាពិសេស អនុសញ្ញាអាស៊ាន និងផែនការសកម្មភាពអាស៊ាន ប្រឆាំងការជួញដូរមនុស្ស អនុស្សរណៈ នៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី និងគោលនយោបាយជាតិពាក់ព័ន្ធនានា ) ។

២. កសាងបន្ថែមច្បាប់ និងបទដ្ឋានគតិយុត្តដែលចាំបាច់ ក្នុងការឆ្លើយតបទៅ នឹងបញ្ហាថ្មី

៣. ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សឆ្លង ដែន ។

## ខ.៤.២. យុទ្ធសាស្ត្រទី២ ៖ លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់ នៃអំពើជួញដូរមនុស្ស

**លទ្ធផលរំពឹងទុក ៖**

១. ការធ្វើចំណាកស្រុករបស់ពលករ នឹងត្រូវបានគ្រប់គ្រង ផ្តល់កិច្ចការពារ និង ផ្តល់ភាពស្របច្បាប់ដែលងាយស្រួល និងអាចទទួលបានឆាប់រហ័ស ដើម្បី បង្ការទប់ស្កាត់ ប្រព័ន្ធនាំពលករចេញដោយខុសច្បាប់ ។

២. បុរេសកម្មដើម្បីបង្ការ ទប់ស្កាត់ រារាំង អំពើជួញដូរ និងកេងប្រវ័ញ្ចលើមនុស្ស គ្រប់រូបភាព ។

៣. គ្រប់សមាសភាពក្នុងសង្គម នឹងចូលរួមបង្ការ ឬទប់ស្កាត់ និងពង្រីកសកម្ម ភាពអប់រំផ្សព្វផ្សាយកាន់តែទូលំទូលាយ តាមគ្រប់រូបភាព ដើម្បីដោះស្រាយ តម្រូវការនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយផ្តោតលើការយល់ ដឹង និងការផ្លាស់ប្តូរឥរិយាបថដែលអវិជ្ជមាន និងប្រកបដោយគ្រោះថ្នាក់ ។

### ខ.៥.៣. យុទ្ធសាស្ត្រទី៣ ៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

**លទ្ធផលរំពឹងទុក ៖**

១. កិច្ចសហការរវាង ស្ថាប័នជំនាញអនុវត្តច្បាប់ តុលាការ និង មន្ត្រីសង្គមកិច្ច ត្រូវបានពង្រឹង ទាំងនៅក្នុងប្រទេស និងរវាងប្រទេសកម្ពុជា និងប្រទេសគោលដៅ ដើម្បីយុត្តិធម៌ជនរងគ្រោះ ។

២. ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីក្នុងស្ថាប័នអយ្យការកាន់តែប្រសើរឡើង ក្នុងការដោះស្រាយករណីជួញដូរមនុស្ស ។

### ខ.៥.៤. យុទ្ធសាស្ត្រទី៤ ៖ បង្កើនកិច្ចការពារជនរងគ្រោះ ជាពិសេស ស្ត្រី និងកុមារ

**លទ្ធផលរំពឹងទុក ៖**

១. ជនរងគ្រោះនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់ ជាពិសេសលើស្ត្រី និងកុមារ ទទួលបានការកំណត់អត្តសញ្ញាណជាក់លាក់ និងមានលទ្ធភាពទទួលបានសេវាសមស្រប និងការថែទាំប្រកបដោយគុណភាព ។

២.កិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល កាន់តែល្អប្រសើរ ដែលធ្វើឲ្យជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ទទួលបានសេវាគាំទ្រ និងថែទាំ បានឆាប់រហ័សដល់ដៃ និងឆ្លើយតបនឹងតម្រូវការចាំបាច់ រួមទាំងការស្តារនីតិសម្បទា ការធ្វើមាតុភូមិនិវត្តន៍ ការផ្តល់ជំនួយផ្នែកច្បាប់ និងការធ្វើសមាហរណកម្មជាដើម ។

## គ. ការត្រួតពិនិត្យ និងវាយតម្លៃ

**គោលបំណង ៖**

តាមដានដំណើរការនៃការអនុវត្តសកម្មភាព ដែលបានគ្រោងទុកក្នុងផែនការជាតិ ដើម្បីពិនិត្យមើលភាពរីកចម្រើន និងចំណុចខ្វះចន្លោះ ភាពប្រឈម ឬឧបសគ្គដែលធ្វើឲ្យរាំងស្ទះ ដើម្បីកែលម្អទាន់ពេលវេលា អាចប្រមូលបាននូវមេរៀន បទពិសោធន៍ល្អៗ ដែលត្រូវចងក្រងដើម្បីផ្សព្វផ្សាយ និងអាចប៉ាន់ប្រមាណអំពីផលប៉ះពាល់នានាដែលត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តជំហានបន្តឲ្យកាន់តែល្អប្រសើរ ។

**លទ្ធផលរំពឹងទុក ៖**

១. ធ្វើឲ្យសម្រេចផែនការសកម្មភាពជាតិដោយមានការចូលរួមគាំទ្រ អនុវត្តប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធ។

២. មានយន្តការត្រួតពិនិត្យ តាមដាន វាយតម្លៃ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានការបណ្តុះបណ្តាល និងផែនការការងារច្បាស់លាស់ ។

ខាងក្រោមនេះ ជាគំរូតារាងសកម្មភាព នៃផែនការជាតិសម្រាប់អនុវត្តក្នុងឆ្នាំ២០១៧ និង២០១៨ ដែលសូមស្នើសុំឲ្យក្រុមការងារអន្តរក្រសួងស្ថាប័នទាំង៦ (គឺក្រុមការងារបង្ការទប់ស្កាត់ ក្រុមការងារការពារជនរងគ្រោះ ក្រុមការងារអនុវត្តច្បាប់ ក្រុមការងារយុត្តិធម៌ ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ក្រុមការងារទេសន្តរប្រវេសន៍) ក្រសួង ស្ថាប័ន អង្គភាព គណៈកម្មាធិការរាជធានីខេត្តបន្តរៀបចំលម្អិត ដើម្បីជាមូលដ្ឋានក្នុងការអនុវត្ត ឲ្យបានព្រមៗគ្នា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានជោគជ័យតាមការគ្រោងទុក៖

# គំរូតារាងសកម្មភាព

## យុទ្ធសាស្ត្រទី១ ៖ លើកកម្ពស់ការអនុវត្តច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

| លទ្ធផលរំពឹងទុក | ចង្កោមសកម្មភាព | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ស្ថាប័នចូលរួម | ពេលវេលាអនុវត្ត | ប្រភពធនធាន |
|---|---|---|---|---|---|---|
| ១.១. លើកកម្ពស់ការ យល់ដឹង និងការប្រើ ប្រាស់លិខិតុបករណ៍ និងបទដ្ឋានគតិយុត្តិ ដែលពាក់ព័ន្ធនៅថ្នាក់ជាតិ និងអន្តរជាតិ សម្រាប់ការបង្ការទប់ស្កាត់ និងលុបបំបាត់បទល្មើសជួញដូរមនុស្ស និងរាល់ទម្រង់ដែលពាក់ព័ន្ធ | **១.១.១. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់** | | | | | |
| | - បើកវគ្គបណ្តុះបណ្តាល ជំនាញ និងច្បាប់ពាក់ព័ន្ធដល់មន្ត្រីអនុវត្តច្បាប់គ្រប់ថ្នាក់ | | ក្រុមការងារអនុវត្តន៍ច្បាប់<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បើកវគ្គបណ្តុះបណ្តាល ក្បួននីតិវិធីប្រតិបត្តិការស្តង់ដា ដល់នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | | ក្រុមការងារអនុវត្តន៍ច្បាប់<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - ពង្រឹងការអនុវត្តច្បាប់ដើម្បីយុត្តិធម៌ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសំណងរដ្ឋប្បវេណី និងសំណងបដិទាន | | ក្រសួងមហាផ្ទៃ<br>ក្រសួងយុត្តិធម៌<br>ក្រសួង ស.អ.យ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | **១.១.២. ការប្រមូល និងចងក្រងទិន្នន័យ** | | | | | |
| | - ប្រមូលទិន្នន័យបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ | | អគ្គលេខាធិការដ្ឋាន<br>គ.ជ.ប.ជ<br>ក្រុមអនុវត្តន៍ច្បាប់ | | | |
| | - ប្រមូលទិន្នន័យផ្តន្ទាទោសពាក់ព័ន្ធអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ នៅដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជម្រះក្តី | | ក្រសួងយុត្តិធម៌<br>អគ្គលេខាធិការដ្ឋាន<br>គ.ជ.ប.ជ | | | |
| | - រៀបចំគោលនយោបាយការងារឆ្លងដែនរយៈពេលខ្លី | | គ.ជ.ប.ជ<br>ក្រសួងមហាផ្ទៃ<br>ក្រសួង ក.ប.វ | | | |
| | - ជំរុញ និងតាមដានការអនុវត្តអនុស្សរណៈ កិច្ចព្រម | | គ.ជ.ប.ជ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ព្រៀងទ្វេភាគី ពហុភាគី និងផែនការសកម្មភាព ដែលបានគ្រោងទុក | | ក្រសួងពាក់ព័ន្ធ | | | |
| **១.២. កសាងបន្ថែមច្បាប់ និង បទដ្ឋានគតិយុត្តដែលចាំបាច់ ក្នុងការឆ្លើយតបទៅនឹងបញ្ហាថ្មី** | **១.២.១. ការកសាងលិខិតបទដ្ឋានគតិយុត្ត** | | | | | |
| | - រៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការផ្តល់នីតិសម្បទាដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះ | | ក្រសួង ស.អ.យ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បង្កើតនីតិវិធីប្រតិបត្តិបទដ្ឋាន (SOP) ក្រោមអនុស្សរណៈទ្វេភាគីជាមួយប្រទេសថៃ និងកែសម្រួល (SOP) ជាមួយប្រទេសវៀតណាម | | ក្រសួង ស.អ.យ<br>ក្រសួង ក.ប.ទ.ស.អ | | | |
| | **១.២.២. ជំរុញការចុះហត្ថលេខាលើសន្ធិសញ្ញា និងកិច្ចព្រមព្រៀងទ្វេភាគីនានា** | | | | | |
| | - ត្រៀមចុះសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ (MLA) រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង ឡាវ រុស្ស៊ី និង កូរ៉េ | | ក្រសួងយុត្តិធម៌<br>ក្រសួង ក.ប.ទ.ស.អ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - ត្រៀមចុះសន្ធិសញ្ញា ស្តីពីការបញ្ជូនទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស ប៉េរូ ឡាវ និងរុស្ស៊ី | | ក្រសួងយុត្តិធម៌<br>ក្រសួង ក.ប.ទ.ស.អ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | **១.២.៣. ធ្វើសេចក្តីព្រាងច្បាប់ឆ្លើយតបទៅនឹងបញ្ហាថ្មី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស** | | | | | |
| | - បង្កើតសេចក្តីព្រាងច្បាប់ ស្តីពីការបង្ក្រាបអំពើរត់ពន្ធមនុស្ស | | ក្រសួងយុត្តិធម៌<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បង្កើតសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងការពពោះជំនួស | | ក្រសួងកិច្ចការនារី<br>ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - ជំរុញឲ្យដំណើរការនូវនីតិវិធីស៊ើបអង្កេតសម្ងាត់ (UIA) | | ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | អង្គការដៃគូពាក់ព័ន្ធ | | | |
| **១.៣. ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សឆ្លងដែន** | **១.៣.១. ពិនិត្យ វិភាគ និងអនុវត្តន៍លិខិតុបករណ៍ពាក់ព័ន្ធនានា** | | | | | |
| | - ពិនិត្យ និងវិភាគលិខិតុបករណ៍គតិយុត្តនីតិវិធីជាតិ គោលនយោបាយតំបន់ និងអន្តរជាតិដែលមានស្រាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដែលបានចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង UNTOC រកអនុសាសន៍សម្រាប់កែលម្អ | | ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ | | | |
| | - គាំទ្រគោលនយោបាយអាស៊ានពាក់ព័ន្ធ សំធីស៊ី និងខមមីត | | ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ<br>សំធីស៊ី | | | |
| | - ចូលរួម និងសម្របសម្រួលកិច្ចប្រជុំ ស្តីពីការរៀបចំកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា និងការអនុវត្តគោលការណ៍ណែនាំជាមួយប្រទេសពាក់ព័ន្ធ មានជាអាទិ៍ប្រទេសម៉ាឡេស៊ី ប្រទេសចិន ។ល។ ព្រមទាំងអនុសាសន៍កែលម្អចាំបាច់ | | ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួង ក.ប.វ<br>អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ<br>ខមមីត/ក.ក.ន<br>សំធីស៊ី | | | |
| | **១.៣.២. ជំរុញការអនុវត្តអនុស្សរណៈ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី** | | | | | |
| | - បង្កើតការអនុវត្តគោលការណ៍ណែនាំនីតិវិធីប្រតិបត្តិដ្ឋាន SOPs និងកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នាទ្វេភាគី ពហុភាគី ដែលជួយដល់ការអនុវត្តគោលនយោបាយបទដ្ឋានអប្បបរមា | | ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួងមហាផ្ទៃ<br>ក្រសួង ក.ប.វ<br>ក្រសួង ស.អ.យ<br>ខមមីត/ក.ក.ន | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ | | | |
| | - បន្តអនុវត្តន៍ផែនការទី៤ សម្រាប់មហាអនុតំបន់មេគង្គ SPA IV | | ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ<br>ខមមីត/ក.ក.ន<br>សំធីស៊ី | | | |
| | - រៀបចំ ឬចូលរួមកិច្ចប្រជុំ ខមមីត ថ្នាក់មហាអនុតំបន់មេគង្គ និងប្រទេសដែលពាក់ព័ន្ធ | | ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ<br>ខមមីត/ក.ក.ន<br>សំធីស៊ី | | | |
| | - រៀបចំ និងចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី នៅមហាអនុតំបន់មេគង្គ | | ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ<br>ខមមីត/ក.ក.ន<br>សំធីស៊ី | | | |
| | - ប្រជុំពិភាក្សាក្នុងចំណោមប្រទេសបញ្ជូនពលករ ដើម្បីកំណត់រកបញ្ហារួម និងដំណោះស្រាយរួម ដើម្បីការពារសុវត្ថិភាព និងផលប្រយោជន៍ពលករទេសន្តរប្រវេសន៍ ដែលបាននិងកំពុងនៅធ្វើការនៅប្រទេសគោលដៅ | | គ.ជ.ប.ជ<br>ក្រសួង ក.ប.វ<br>ក្រសួង ក.ប.ទ.ស.អ | | | |
| | - ជួបពិភាក្សាក្នុងកិច្ចប្រជុំតំបន់រវាងប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីមានវិធានការការពារសុវត្ថិភាពពលករ | | គ.ជ.ប.ជ<br>ខមមីត/ក.ក.ន | | | |
| | - រៀបចំកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន | | គ.ជ.ប.ជ | | | |
| | - រៀបចំកិច្ចប្រជុំទ្វេភាគី កម្ពុជា-ឥណ្ឌា | | គ.ជ.ប.ជ | | | |
| | - សហការផ្លាស់ប្តូរព័ត៌មានជាមួយប្រទេសថៃ ឥណ្ឌូនេស៊ី វៀតណាម ម៉ាឡេស៊ី ដើម្បីស្រាវជ្រាវ | | ក្រុមការងារអនុវត្តច្បាប់អង្គការដៃគូពាក់ព័ន្ធ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | រកមេខ្យល់ជួញដូរពលកម្មឆ្លងដែន | | | | | |
| | - ជំរុញឲ្យបន្តការអនុវត្តកិច្ចសហការរវាងអង្គភាពឯកទេសកម្ពុជា-ថៃ (ជនបង្គោល) | | អគ្គ.នគរបាលជាតិ<br>AAPTIP | | | |

## យុទ្ធសាស្ត្រទី២ ៖ លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស

| លទ្ធផលរំពឹងទុក | ចង្កោមសកម្មភាព | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ស្ថាប័នចូលរួម | ពេលវេលាអនុវត្ត | ប្រភពធនធាន |
|---|---|---|---|---|---|---|
| **២.១. ការធ្វើចំណាកស្រុករបស់ពលករ នឹងត្រូវបានគ្រប់គ្រង ផ្តល់កិច្ចការពារ និងផ្តល់ភាពស្របច្បាប់ដែលងាយស្រួល និងអាចទទួលបានឆាប់រហ័ស ដើម្បីបង្ការ ទប់ស្កាត់ប្រព័ន្ធនាំពលករចេញដោយខុសច្បាប់** | **២.១.១. ការពង្រឹងការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ** | | | | | |
| | - ពង្រឹងការគ្រប់គ្រងទីភ្នាក់ងារឯកជនស្របច្បាប់ តាមអនុក្រឹត្យលេខ១៩០ របស់រាជរដ្ឋាភិបាលកម្ពុជា និងជំរុញការអនុវត្តប្រកាសទាំង៨ | | ក្រសួង ក.ប.វ<br>អគ្គ.នគរបាលជាតិ<br>ក្រុមការងារទេសន្តរប្រវេសន៍ | | | |
| | - រៀបចំក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសពលករស្របច្បាប់ ដើម្បីបង្កើនប្រសិទ្ធភាពនៃការជ្រើសរើស កិច្ចសន្យាការងារ ការបញ្ជូន ការដាក់ក្នុងកន្លែងការងារ និងការគ្រប់គ្រងការពារពលករដែលត្រូវទៅធ្វើការនៅក្រៅប្រទេស រួមទាំងការវិលត្រឡប់(ជាពិសេសផ្តោតលើប្រទេសម៉ាឡេស៊ី) | | ក្រសួង ក.ប.វ<br>ILO<br>ACRA, MAC,... | | | ILO |
| | - ស៊ើបអង្កេត តាមដាន និងបង្ក្រាបក្រុមហ៊ុនជ្រើសរើសពលករដែលមិនស្របច្បាប់ | | អង្គភាពជំនាញនគរបាលយុត្តិធម៌ | | | |
| | - តម្លើងបញ្ជីទិន្នន័យពាក់ព័ន្ធនឹងក្រុមហ៊ុនជ្រើសរើសពលករ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ | | អគ្គ.នគរបាលជាតិ | | | |
| | **២.១.២. គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងកិច្ចការពារពលករទេសន្តរប្រវេសន៍** | | | | | |
| | - ជំរុញ និងតាមដានការអនុវត្តអនុស្សរណៈ កិច្ចព្រមព្រៀង ទ្វេភាគី ពហុភាគី និងផែនការសកម្មភាព | | គ.ជ.ប.ជ<br>ក្រសួងពាក់ព័ន្ធ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ដែលបានគ្រោងទុកសម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ខុសច្បាប់ | | | | | |
| | - រៀបចំគោលនយោបាយការងារឆ្លងដែនរយៈពេលខ្លី | | គ.ជ.ប.ជ<br>ក្រសួងមហាផ្ទៃ<br>ក្រសួង ក.ប.វ | | | |
| | - ជំរុញការចុះហត្ថលេខាលើអនុស្សរណៈរវាងកម្ពុជា-ម៉ាឡេស៊ី និងកម្ពុជា-ឥណ្ឌា ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស | | គ.ជ.ប.ជ | | | |
| | - លើកកម្ពស់ការផ្តល់សេវានិងឯកសារស្របច្បាប់ដល់ពលករ ដើម្បីធ្វើទេសន្តរប្រវេសន៍ការងារដោយសុវត្ថិភាព | | ក្រសួងមហាផ្ទៃ<br>ក្រសួង ក.ប.ទ.ស.អ<br>ក្រសួង ក.ប.វ | | | |
| | - បង្កើតយន្តការ និងបង្កើនកិច្ចសហការជាមួយប្រទេសគោលដៅ ដើម្បីផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជានៅក្រៅប្រទេស | | ក្រសួងមហាផ្ទៃ<br>ក្រសួង ក.ប.ទ.ស.អ<br>ក្រសួង ក.ប.វ | | | |
| | - រៀបចំបង្កើតមជ្ឈមណ្ឌលសំចត និងស្ថានីតិសម្បទា សម្រាប់សម្របសម្រួលការងារការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សឆ្លងដែន | | ក្រសួង ស.អ.យ<br>ខេត្តបាត់ដំបង ប៉ៃលិន<br>បន្ទាយមានជ័យ កោះកុង | | | |
| | - រៀបចំបង្កើតមណ្ឌលតាមបណ្តាច្រកទ្វារព្រំដែនសំខាន់ៗ ដើម្បីផ្តល់ព័ត៌មាន និងសេវាចាំបាច់សម្រាប់ពលករចេញចូលឆ្លងកាត់ព្រំដែន | | គ.ជ.ប.ជ<br>(ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួង ស.អ.យ)<br>គ.ខ.ប.ជខេត្តជាប់ព្រំដែន | | | |
| | - រៀបចំប្រព័ន្ធទិន្នន័យ ពាក់ព័ន្ធនឹងការតាមដានលំហូរចេញចូលរបស់ពលករ ទាំងស្របច្បាប់និងមិនស្របច្បាប់ | | គ.ជ.ប.ជ<br>អគ្គ.អន្តោប្រវេសន៍<br>អង្គការដៃគូពាក់ព័ន្ធ | | | |

| | | | | | |
|---|---|---|---|---|---|
| ២.២. បុរេសកម្មដើម្បីបង្ការ ទប់ស្កាត់ រារាំង អំពើជួញដូរ និងកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព | **២.២.១. ការកសាងសមត្ថភាព** | | | | |
| | - បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ មន្ត្រីអន្តោប្រវេសន៍ មន្ត្រីអប់រំ មន្ត្រីសង្គមកិច្ច មន្ត្រីការងារ និងមន្ត្រីពាក់ព័ន្ធដទៃទៀត ស្តីពីសិទ្ធិមនុស្ស សិទ្ធិកុមារ និងយេនឌ័រ ពាក់ព័ន្ធរាល់ទម្រង់នៃអំពើជួញដូរមនុស្ស | | គ.ជ.ប.ជ<br>ក្រសួងមហាផ្ទៃ<br>ក្រសួង អ.យ.ក<br>ក្រសួង ក.ប.យ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - សិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការលើកម្ពស់សុវត្ថិភាពស្ត្រី និងកុមារក្នុងវិស័យទេសចរណ៍ ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានតាមគ្រប់រូបភាពក្នុងវិស័យទេសចរណ៍ | | ក្រសួងទេសចរណ៍<br>ក្រសួងមហាផ្ទៃ<br>គ.រ.ប.ជ/គ.ខ.ប.ជ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - សិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ទេសចរណ៍ផ្លូវភេទ | | ក្រសួងទេសចរណ៍<br>អគ្គ.នគរបាលជាតិ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បន្តបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប | | គ.ជ.ប.ជ<br>ក្រសួង ស.អ.យ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បន្តបណ្តុះបណ្តាលស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងគោលនយោបាយ និងអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស | | ក្រសួង ស.អ.យ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | **២.២.២. ការសិក្សាស្រាវជ្រាវ** | | | | |
| | - សិក្សាវិភាគទៅលើចំណូលចំណាយ (សង្គម) | | គ.ជ.ប.ជ<br>UN-ACT | | | UN-ACT |

| | | | | | | |
|---|---|---|---|---|---|---|
| | នៃការធ្វើទេសន្តរប្រវេសន៍ ( Social Cost-Benefits analysis of migration cycle ) | | Caritas Cambodia | | | Caritas Cambodia |
| | - សិក្សាស្រាវជ្រាវអំពីស្ថានភាពពលករនៅក្រៅប្រទេស ជាពិសេសប្រទេសថៃ ក្នុងនិងក្រោយពេលផ្តល់ភាពស្របច្បាប់ និងក្រោយពេលវិលត្រឡប់មកកម្ពុជាវិញ | | គ.ជ.ប.ជ<br>ក្រុមការងារទេសន្តរប្រវេសន៍<br>ក្រុមការងារការពារជនរងគ្រោះ | | | |
| | **២.២.៣. កាត់បន្ថយភាពរងគ្រោះដល់ជនមុនសញ្ញារងគ្រោះ** | | | | | |
| | - ចុះអធិការកិច្ចនៅតាមបណ្តារោងចក្រ សហគ្រាស ជាពិសេសសិប្បកម្មឡឥដ្ឋ ដើម្បីការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ | | ក្រសួង ក.ប.វ<br>គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ | | | |
| | - ទប់ស្កាត់អំពើកេងប្រវ័ញ្ច និងរំលោភបំពានទៅលើកុមារអនាថា កុមារលក់ដូរ និងកុមារសុំទានតាមដងផ្លូវសាធារណៈ | | ក្រសួង ស.អ.យ<br>អាជ្ញាធរពាក់ព័ន្ធ | | | |
| | - លើកកម្ពស់សុវត្ថិភាពស្ត្រី និងកុមារក្នុងវិស័យទេសចរណ៍ ជាពិសេសលុបបំបាត់ទេសចរណ៍ផ្លូវភេទលើកុមារ | | ក្រសួងទេសចរណ៍<br>អាជ្ញាធរពាក់ព័ន្ធ | | | |
| | **២.២.៤. ទប់ស្កាត់ រារាំងតម្រូវសេវាកម្មដែលទំនោរទៅរកការជួញដូរមនុស្ស** | | | | | |
| | - បន្តវិធានការល្បាត និងឃ្លាំមើលចំពោះគោលដៅសង្ស័យ ដែលអាចនឹងមានបទល្មើសជួញដូរមនុស្សកើតឡើង | | ក្រុមការងារអនុវត្តច្បាប់<br>អង្គភាពជំនាញនគរបាលយុត្តិធម៌ | | | |
| | - ស៊ើបអង្កេត និងបង្ក្រាបគោលដៅប្រព្រឹត្តបទល្មើសតាមបណ្តាសេវាកំសាន្ត និងសហគមន៍ | | ក្រុមការងារអនុវត្តន៍ច្បាប់<br>អង្គភាពជំនាញនគរបាលយុត្តិធម៌ | | | |
| | - បន្តស៊ើបអង្កេតករណីអន្តរការរីនៃការពពោះជំនួស | | ក្រុមការងារអនុវត្តន៍ច្បាប់ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ដែលកើតឡើងតាមសហគមន៍ | | អង្គភាពជំនាញនគរបាលយុត្តិធម៌ | | | |
| | - ចុះអប់រំប្រជាពលរដ្ឋនៅតាមបណ្ដាសហគមន៍ជនបទ ដែលប្រឈមនឹងហានិភ័យខ្ពស់ | | គ.ជ.ប.ជ<br>គ.រ.ប.ជ/គ.ខ.ប.ជ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - ធ្វើបច្ចុប្បន្នភាពគោលដៅសង្ស័យប្រព្រឹត្តបទល្មើស (ចុះធ្វើកិច្ចសន្យាតាមខារ៉ាអូខេ ក្លឹបកំសាន្ត ម៉ាស្សា និងគោលដៅសង្ស័យដែលមានអំពើជួញដូរមនុស្សផ្សេងទៀត) | | ក្រុមការងារអនុវត្តន៍ច្បាប់នគរបាលប្រឆាំងការជួញដូរមនុស្ស | | | |
| | **២.២.៥. ការបង្ការទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរនិងជនបរទេស** | | | | | |
| | - ផ្សព្វផ្សាយ អប់រំព័ត៌មានជាសាធារណៈ ស្ដីពីការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសមិនស្របច្បាប់ | | ក្រសួងមហាផ្ទៃ<br>ក្រសួង ក.ប.ទ.ស.អ | | | |
| | - កែសម្រួលអនុក្រឹត្យលេខ ១៨៣ អនក្រ និងបែបបទនីតិវិធី ស្ដីពីការស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស | | ក្រសួងមហាផ្ទៃ<br>ក្រសួង ក.ប.ទ.ស.អ | | | |
| **២.៣.គ្រប់សមាសភាពក្នុងសង្គមនឹងចូលរួមបង្ការ ឬទប់ស្កាត់ និងពង្រីកសកម្មភាពអប់រំ ផ្សព្វផ្សាយកាន់តែទូលំទូលាយ តាមគ្រប់រូបភាព ដើម្បីដោះស្រាយតម្រូវការនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយផ្ដោតលើការយល់ដឹង និងការផ្លាស់ប្ដូរឥរិយាបថដែលអវិជ្ជមាន និង** | **២.៣.១ លើកកម្ពស់ការយល់ដឹង ជាសាធារណៈតាមគ្រប់រូបភាព** | | | | | |
| | - សហការគាំទ្រជាមួយស្ថាប័នថ្នាក់ជាតិ-ក្រោមជាតិ អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ បន្តផ្សព្វផ្សាយស្ដីពីការការពារខ្លួនពីភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈវេទិកាសាធារណៈ ។ | | គ.ជ.ប.ជ<br>គ.រ.ប.ជ/គ.ខ.ប.ជ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បន្តផ្សព្វផ្សាយពីសុវត្ថិភាព និងផលប៉ះពាល់នៃចំណាកស្រុក តាមរយៈកម្មវិធីភូមិឃុំមានសុវត្ថិភាព និងកម្មវិធីដ៏ទៃទៀតនៅតាមសហគមន៍ជនបទ | | គ.រ.ប.ជ/គ.ខ.ប.ជ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ប្រកបដោយគ្រោះថ្នាក់ | ដូចជាកម្មវិធីអនាម័យទឹកស្អាត ឥណទាន អេដស៍ និងយេនឌ័រ | | | | | |
| | - រៀបចំពិធីបួងសួងអន្តរសាសនាកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | | គ.ជ.ប.ជ<br>អ្នកដឹកនាំសាសនា<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - ការអប់រំអំពីចំណាកស្រុក បញ្ជ្រាបការអប់រំ ស្តីពីចំណាកស្រុកដោយសុវត្ថិភាព ផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ក្លែងក្លាយ ផ្ទុយពីធន្ទះ ... តាមរយៈអ្នកដឹកនាំសាសនា ។ | | គ.ជ.ប.ជ<br>ក្រសួងធម្មការ<br>និងសាសនា | | | Caritas Cambodia |
| | - រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ | | គ.ជ.ប.ជ<br>គ.រ.ប.ជ/គ.ខ.ប.ជ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - ផ្សព្វផ្សាយអំពីនីតិវិធី ដើម្បីផ្តល់នូវការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនៃអំពើហិង្សាលើស្ត្រីដល់អាជ្ញាធរមូលដ្ឋាន | | ក្រសួងកិច្ចការនារី<br>អគ្គ.នគរបាលជាតិ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - ផ្សព្វផ្សាយព័ត៌មានអំពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជំនាញរឹង និងជំនាញទន់ សម្រាប់អ្នករៀនចប់ភូមិសិក្សា ឬអ្នកបោះបង់ការសិក្សា និងទាក់ទងរកការងារតាមបណ្តារោងចក្រសហគ្រាស សម្រាប់ផ្តល់ការងារពេលរៀនចប់ | | ក្រសួង អ.យ.ក | | | ILO |
| | - អប់រំការផ្លាស់ប្តូរទស្សនៈ និងឥរិយាបទ មន្ត្រី និងប្រជាពលរដ្ឋ កាត់បន្ថយហានិភ័យដោយភាពរងគ្រោះ | | គ.ជ.ប.ជ | | | AAPTIP |
| | - បង្កើតកម្មវិធីផ្សព្វផ្សាយយុទ្ធសាស្ត្របង្ការទប់ស្កាត់ដល់កម្មកររោងចក្រ សហគ្រាស សហគមន៍ | | ក្រសួង អ.យ.ក<br>ក្រសួង ក.ប.វ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | និងតាមប្រព័ន្ធផ្សព្វផ្សាយនានា | | IOM, Unicef .. | | | |
| | **២.៣.២. សកម្មភាពអប់រំតាមសាលារៀន** | | | | | |
| | - ជំរុញអនុវត្តន៍កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមសាលារៀន គ្រប់ភូមិសិក្សារដ្ឋ និងឯកជន | | ក្រសួង អ.យ.ក<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បង្កើតបណ្តាញសុវត្ថិភាពការពារកុមារក្នុងសាលារៀន | | ក្រសួង អ.យ.ក<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បង្កើនការយល់ដឹងដល់គណៈគ្រប់គ្រងសាលា និងគ្រូគរុកោសល្យ អំពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារតាមសាលារៀន | | គ.ជ.ប.ជ<br>ក្រសួង អ.យ.ក<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | **២.៣.៣. ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន** | | | | | |
| | - បង្កើតសារ ខ្សែវីដេអូ សាររូបភាព ខិតប័ណ្ណ លេខទូរស័ព្ទពិសេស និងការសម្តែងរឿងខ្លីៗ សម្រាប់អប់រំផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងវេទិកាសាធារណៈ ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមគ្រប់រូបភាពជាសាធារណៈ និងជាពិសេសតាមបណ្តាសហគមន៍ជនបទ | | គ.ជ.ប.ជ<br>ក្រសួងមហាផ្ទៃ<br>ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>ក្រសួងព័ត៌មាន<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>អង្គការដៃគូពាក់ព័ន្ធនិងផ្នែកឯកជន | | | ILO, UN-ACT |
| | - ប្រឡងប្រណាំងសរសេរកំណាព្យ ចម្រៀង និងអំណាន ក្នុងចំណោមសិស្សនិងអ្នកពាក់ព័ន្ធ អំពីប្រធានបទបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងបង្កើតសម្ភារអប់រំផ្សព្វផ្សាយ (វីដេអូខ្លី...) | | ក្រសួង អ.យ.ក<br>ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>ក្រសួងព័ត៌មាន<br>អង្គការដៃគូពាក់ព័ន្ធ | | | |

## យុទ្ធសាស្ត្រទី៣ ៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបអំពើជួញដូរមនុស្ស

| លទ្ធផលរំពឹងទុក | ចង្កោមសកម្មភាព | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ស្ថាប័នចូលរួម | ពេលវេលាអនុវត្ត | ប្រភពធនធាន |
|---|---|---|---|---|---|---|
| ៣.១. កិច្ចសហការរវាងស្ថាប័នជំនាញអនុវត្តច្បាប់ តុលាការ និងមន្ត្រីសង្គមកិច្ច ត្រូវបានពង្រឹងទាំងនៅក្នុងប្រទេស និងរវាងប្រទេស កម្ពុជា និងប្រទេសគោលដៅ ដើម្បីយុត្តិធម៌ជនរងគ្រោះ | ៣.១.១. ការសម្របសម្រួល និងកិច្ចសហការរវាងស្ថាប័នអនុវត្តច្បាប់ ស្ថាប័នតុលាការ និងសេវាសង្គម | | | | | |
| | - ប្រមូលព័ត៌មាន ស៊ើបអង្កេត ស្រាវជ្រាវ និងបង្ក្រាបមេខ្យល់អូសទាញ ឬបោកបញ្ឆោតស្ត្រី និងអនីតិជនដើម្បីរៀបអាពាហ៍ពិពាហ៍ទៅក្រៅប្រទេស ការពពោះជំនួស ការធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ ធ្វើពេស្យាចារ ជួញដូរសរីរាង្គ ។ល។ | | អង្គភាពជំនាញនគរបាលយុត្តិធម៌ | | | |
| | ៣.១.២. ពង្រឹងប្រព័ន្ធប្រមូលទិន្នន័យនៃការផ្តន្ទាទោសអំពើជួញដូរមនុស្ស | | | | | |
| | - ប្រមូលទិន្នន័យបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ | | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមអនុវត្តន៍ច្បាប់ | | | |
| | - ប្រមូលទិន្នន័យផ្តន្ទាទោសពាក់ព័ន្ធអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ នៅដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជម្រះក្តី | | ក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | | | |
| | - ប្រមូលទិន្នន័យជនរងគ្រោះដែលទទួលបានសំណងរដ្ឋប្បវេណី និងសំណងបជិទាន ក្នុងរឿងក្តីជួញដូរមនុស្ស | | ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួង ស.អ.យ អង្គការដៃគូពាក់ព័ន្ធ | | | |
| | ៣.១.៣. ពង្រឹងការប្រើប្រាស់យន្តការក្នុងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ | | | | | |
| | - សហការផ្លាស់ប្តូរព័ត៌មានអំពីយន្តការអនុវត្តច្បាប់រវាងប្រទេសកម្ពុជា និងប្រទេសពាក់ព័ន្ធ (ថៃ | | ក្រសួង ក.ប.ទ.ស.អ ក្រសួងយុត្តិធម៌ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ឥណ្ឌូនេស៊ី វៀតណាម ម៉ាឡេស៊ី) ដើម្បីស្រាវជ្រាវរកមេខ្យល់ជួញដូរពលកម្មឆ្លងដែន | | អគ្គ.នគរបាលជាតិ<br>អគ្គ.អន្តោប្រវេសន៍ | | | |
| | - បង្កើនការយកចិត្តទុកដាក់សង្គ្រោះជនរងគ្រោះនៅក្រៅប្រទេសត្រឡប់មកកម្ពុជាវិញ ។ | | ក្រសួង ក.ប.ទ.ស.អ<br>អគ្គ.នគរបាលជាតិ<br>អគ្គ.អន្តោប្រវេសន៍ | | | |
| | - បង្កើនការស្រាវជ្រាវស្វែងរកភស្តុតាង ដើម្បីដាក់បន្ទុកជនសង្ស័យឲ្យកាន់តែមានប្រសិទ្ធភាព | | ក្រសួងយុត្តិធម៌<br>តុលាការ<br>អយ្យការ<br>អគ្គ.នគរបាលជាតិ | | | |
| | **៣.១.៤.ពង្រឹងកិច្ចសហការរវាងអង្គភាពឯកទេស** | | | | | |
| | - ជំរុញឲ្យបន្តការអនុវត្តកិច្ចសហការរវាងអង្គភាពឯកទេសកម្ពុជា-ថៃ (ជនបង្គោល) | | អគ្គ.នគរបាលជាតិ<br>AAPTIP | | | |
| **៣.២. ពង្រឹងសមត្ថមន្ត្រីអនុវត្តន៍ច្បាប់ និងមន្ត្រីក្នុងស្ថាប័នអយ្យការ កាន់តែប្រសើរឡើងក្នុងការដោះស្រាយករណីជួញដូរមនុស្ស** | **៣.២.១. ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ក្នុងការស៊ើបអង្កេត និងប្រមូលភស្តុតាង** | | | | | |
| | - បើកវគ្គបណ្តុះបណ្តាល ជំនាញ និងច្បាប់ពាក់ព័ន្ធដល់មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ថ្នាក់ | | ក្រុមការងារអនុវត្តន៍ច្បាប់<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បើវគ្គបណ្តុះបណ្តាលក្បួននីតិវិធីប្រតិបត្តិការស្តង់ដា ដល់នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | | ក្រុមការងារអនុវត្តន៍ច្បាប់<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បើកវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស ស្តីពីនីតិវិធីនៃការស៊ើបអង្កេតប្រមូលភស្តុតាងបទល្មើសជួញដូរមនុស្ស | | បណ្ឌិត្យសភានគរបាលកម្ពុជា<br>អង្គការដៃគូពាក់ព័ន្ធ<br>(IJM) | | | |

## យុទ្ធសាស្ត្រទី៤ ៖ លើកកម្ពស់កិច្ចការពារជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ

| លទ្ធផលរំពឹងទុក | ចង្កោមសកម្មភាព | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ស្ថាប័នចូលរួម | ពេលវេលាអនុវត្ត | ប្រភពធនធាន |
|---|---|---|---|---|---|---|
| ៤.១. ជនរងគ្រោះនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់ ជាពិសេសលើស្ត្រី និងកុមារ ទទួលបានការកំណត់អត្តសញ្ញាណជាក់លាក់ និងមានលទ្ធភាពទទួលបានសេវាសមស្រប និងការថែទាំប្រកបដោយគុណភាព | **៤.១.១. ការកំណត់អត្តសញ្ញាណជនរងគ្រោះ** | | | | | |
| | - ជំរុញការអនុវត្តបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្រប ក្នុងប្រទេស និងនៅប្រទេសពាក់ព័ន្ធ | | គ.ជ.ប.ជ<br>ក្រសួង ស.អ.យ<br>ក្រសួង ក.ប.ទ.ស.អ<br>អគ្គ.នគរបាលជាតិ | | | |
| | - ពង្រឹង និងតាមដានអំពីប្រសិទ្ធភាពនៃការអនុវត្តការកំណត់អត្តសញ្ញាណជនរងគ្រោះ | | គ.ជ.ប.ជ<br>ក្រសួង ស.អ.យ | | | |
| | **៤.១.២. ការផ្តល់សេវាកម្ម** | | | | | |
| | - ផ្តល់សេវាបន្ទាន់សមស្របនៅនឹងកន្លែង (សេវាសុខភាព ជម្រកបណ្តោះអាសន្ន ការផ្តល់ប្រឹក្សា សេវាផ្លូវច្បាប់ ...) | | ក្រសួង ស.អ.យ<br>ក្រសួងសុខាភិបាល<br>ក្រសួងយុត្តិធម៌<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| ៤.២. កិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល កាន់តែល្អប្រសើរ ដែលធ្វើឲ្យជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ទទួល បានសេវាគាំទ្រ និងថែទាំបានឆាប់រហ័សដល់ដៃ និងឆ្លើយតបនឹងតម្រូវការចាំបាច់ រួមទាំងការស្តារនីតិសម្បទា ការធ្វើមាតុភូមិនិវត្តន៍ ការផ្តល់ជំនួយ | **៤.២.១. ការពង្រឹងកិច្ចសហការ ដើម្បីផ្តល់សេវា** | | | | | |
| | - សហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការផ្តល់សេវានៅតាមមណ្ឌល ដែលបានបង្កើតតាមបណ្តាខេត្តជាប់ព្រំដែន (កោះកុង បាត់ដំបង បន្ទាយមានជ័យ ស្វាយរៀង) ដើម្បីជួយសម្របសម្រួលដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស | | គ.ជ.ប.ជ<br>ក្រសួង ស.អ.យ<br>ក្រសួង ក.ប.ទ<br>គ.ខ.ប.ជ កោះកុង បាត់ដំបង ស្វាយរៀង បន្ទាយមានជ័យ<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | - បន្តសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការទទួល-បញ្ជូនមាតុភូមិ | | ក្រសួង ស.អ.យ<br>ក្រសួង ក.ប.ទ.ស.អ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| **ផ្នែកច្បាប់ និងការធ្វើសមាហរណកម្មជាដើម** | និវត្តន៍ ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទទៅក្នុងសហគមន៍ | | ក្រសួង អ.យ.ក<br>ក្រសួង ក.ប.វ<br>អាជ្ញាធរមូលដ្ឋាន<br>អង្គការដៃគូពាក់ព័ន្ធ | | | |
| | **៤.២.២. ពង្រឹងការផ្តល់សេវាតាមមណ្ឌល** | | | | | |
| | - បន្តការចុះធ្វើអធិការកិច្ចមជ្ឈមណ្ឌលស្តារនីតិសម្បទារបស់រដ្ឋ និងអង្គការដៃគូ សម្រាប់ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស | | ក្រសួង ស.អ.យ<br>នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន<br>គ.វ.ប.ជ/គ.ខ.ប.ជ | | | |
| | - រៀបចំបែបបទផ្តល់នីតិសម្បទា ដល់មណ្ឌលថៃទាំជំនួស របស់អង្គការ | | ក្រសួង ស.អ.យ | | | |